ព្រឹត្តិបត្រប្រចាំខែ
*Monthly Newsletter*

# ការអប់រំ និង បច្ចេកវិទ្យា
# Education & Technology









ឆ្នាំទី២ លេខ០០៤ ចេញផ្សាយប្រចាំខែមករា-មេសា ឆ្នាំ២០២២

ការិយាល័យ: សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម
ប្រអប់សំបុត្រ: P.O Box ១៦២១ ភ្នំពេញ កម្ពុជា 042-941-481 / 042-941-918 kape@kapekh.org
www.kapekh.org www.facebook.com/kapeaction https://t.me/kapemedia
www.twitter.com/KAPECambodia www.linkedin.com/in/kapecambodia
https://www.instagram.com/kapecambodia/ www.youtube.com/TheKapeCambodia

# មាតិកា

ទំព័រ


១-២ អំពីអង្គការ ខេប ចំនួនគម្រោងកំពុងប្រតិបត្តិ និងម្ចាស់ជំនួយក្នុងឆ្នាំ២០២២

## ១. ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ ( NGS )

៤ ការគ្រប់គ្រងសាលារៀន
៤ អង្គរបិសស្សនាកម្មវិធីសាលារៀនជំនាន់ថ្មី
៥ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ

## ២.ព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាសម្រាប់ការអប់រំ

៧ ការចុះប្រមូលទិន្នន័យក្នុងថាប់ឡែតនៅតាមសាលារៀនគោលដៅ
៧ សុសវែរកម្មវិធីអប់រំអំណានសម្រាប់ការពង្រឹងអំណានដល់កុមារ

## ៣. ការអភិវឌ្ឍគ្រូបង្រៀន

៩ ការប្រើប្រាស់សៀវភៅស្តង់ដាអំណាន
១០ ការរំឭកថ្នាក់ពន្លឿនការសិក្សាថ្នាក់ទី១
១០ ការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែម
១១ ថវិកាអភិវឌ្ឍន៍សាលារៀនទៅកាន់នាយកសាលា
១១ ការបណ្តុះបណ្តាលគ្រូបង្គោលកម្មវិធីបំណិនជីវិត Gap Inc. P.A.C.E.
១៣ ការប្រមូលកុមារក្រៅសាលារៀន ការគូសផែនទីខ្នងផ្ទះ
១៤ ពង្រឹងសមត្ថភាពគ្រូលើការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែម
១៤ គណៈកម្មការសុខភាពតាមសាលារៀន
១៥ ការពង្រឹងតួនាទី ទីប្រឹក្សាកុមារ
១៥ ការពង្រឹងតួនាទីបណ្ណារក្ស
១៦ ការគ្រប់គ្រងបណ្ណាល័យ
១៦ កិច្ចប្រជុំឆ្លុះបញ្ចាំងស្តីពីគ្រូបង្វឹកអំណាន
១៧ វគ្គតម្រង់ទិសស្តីពី តួនាទី និងភារកិច្ចគ្រូស្ម័គ្រចិត្ត
១៧ ការកសាងផែនការអភិវឌ្ឍសាលារៀន
១៨ វគ្គបណ្តុះបណ្តាលស្តីពី ការប្រើប្រាស់សៀវភៅកញ្ចប់ឯកសារបំប៉នបន្ថែម
១៨ កម្មវិធីសិក្សា ICT Computational Thinking
១៩ ប្រព័ន្ធគ្រប់គ្រងទិន្នន័យកុមារ និងយុវជនប្រឈមនឹងហានិភ័យ

## ៤. កម្មវិធីអប់រំបរិយាប័ន្ន

២១ សិស្សងាយរងគ្រោះទទួលបានកង់សម្រាប់ធ្វើដំណើរទៅសាលារៀន
២១ កម្មវិធីចែកអាហារូបករណ៍ដល់សិស្សក្រីក្ររបស់គម្រោង
២២ កិច្ចប្រជុំក្រុមសេនាធិការរបស់គម្រោង KYLA
២៣ ការឆ្លុះបញ្ចាំងការអនុវត្តកម្មវិធីអាហារូបករណ៍
២៣ ការជួយបង្រៀនកុមារតាមខ្នងផ្ទះ
២៤ ការស្រាវជ្រាវបែបចូលរួម
២៤ កម្មវិធីចែកសម្ភារៈសិក្សាជូនដល់សិស្សអាហារូបករណ៍
២៥ ផលផ្លាស់ប្តូរវិជ្ជមានរបស់នាយក និងគណៈកម្មការគ្រប់គ្រងសាលារៀន

## ៥. កម្មវិធីអំណានថ្នាក់ដំបូង

២៨ ការពង្រឹងសមត្ថភាពសិស្សលើផ្នែកអំណានថ្នាក់ដំបូង

## ៦. កម្មវិធីមត្តេយ្យសិក្សា

៣០ ការវាស់ស្ទង់ការអភិវឌ្ឍ និងការហាត់រៀនតាំងពីដំបូងរបស់កុមារតូច
៣០ ការងារបច្ចេកទេស និងការប្រើប្រាស់សៀវភៅសិក្សាគោល

## ៧. រចនាបថហេដ្ឋារចនាសម្ព័ន្ធ

៣២ ការបង្កើតបន្ទប់មត្តេយ្យសិក្សាបែបទំនើប

## ៨. ការអភិវឌ្ឍបណ្ណាល័យ

៣៤ ការអភិវឌ្ឍបណ្ណាល័យធម្មតាទៅជាបណ្ណាល័យស្តង់ដា

## ៩. កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព

៣៦ កម្មវិធីបំណិនជីវិត
៣៦ ឯកសារកម្មវិធីបំណិនជីវិតសម្រាប់បឋមសិក្សា និងមធ្យមសិក្សា
៣៧ បំណិនជីវិតទាក់ទងនឹងទឹកស្អាត និងអនាម័យផ្ទាល់ខ្លួន

## ១០. កម្មវិធីឆ្លើយតបនឹងវិស័យអប់រំក្នុងបរិបទកូវីដ-១៩

៣៩ លើកកម្ពស់ការសិក្សាជាមួយកញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែម

## ១១. ព្រឹត្តិការណ៍ ការស្រាវជ្រាវចំណេះដឹង និងការកំសាន្តផ្សេងៗ

៤១ ការផ្សព្វផ្សាយគម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី
៤២ កិច្ចប្រជុំស្តីពីការពិនិត្យសកម្មភាពក្នុងការគាំទ្រវិទ្យាជាតិអប់រំ
៤៣ កម្មវិធីបើកសម្ពោធគម្រោងលើកកម្ពស់គុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា
៤៤ កម្មវិធីបើកសម្ពោធគម្រោងបង្កើនភាពងាយស្រួលដល់ការអប់រំនិងលទ្ធភាពទទួលបានការងារតាមរយៈការចូលរួមពីសហគមន៍ ( BMZ )
៤៤ ខេប ចូលរួមទទួលពានរង្វាន់ Lotus Leadership នៅក្នុងទីក្រុងញូវយ៉ក
៤៥ នាមសិស្សានុសិស្ស
៤៥ ក្បួនណាប្រល័យការសិក្សាខ្ញុំ
៤៦ ទម្រាំតែអាចរស់មកដល់ថ្ងៃនេះ !
៤៦ មតិអ្នកអាន

# ព្រឹត្តិបត្រ "ការអប់រំ និងបច្ចេកវិទ្យា"

## រៀបចំផលិត និងចេញផ្សាយដោយ

| | | |
|---|---|---|
| លោក អឿ សារីន | មន្ត្រីទំនាក់ទំនងជាន់ខ្ពស់ | រៀបចំផែនការ បង្កើតទម្រង់ និងរចនា |
| កញ្ញា ជ្រន ភាត់ថា | ជំនួយការផ្នែកទំនាក់ទំនង | ប្រមូល និងសរសេរព័ត៌មាន |

## ជំនួយផ្នែកបច្ចេកទេស និងទិន្នន័យ

| | | |
|---|---|---|
| លោក ឈួន តារា | មន្ត្រីបច្ចេកវិទ្យាព័ត៌មានជាន់ខ្ពស់ | ជំនួយការផ្នែក IT |
| លោក ទ៉ាន់ សុខសារៈ | អ្នកគ្រប់គ្រងផ្នែកតាមដាន វាយតម្លៃ និងទិន្នន័យ | ជំនួយការផ្នែកទិន្នន័យ |
| លោក ម៉ៃ សុខឃា | មន្ត្រីព័ត៌មានវិទ្យា | ជំនួយការ IT |

## ត្រួតពិនិត្យ និងកែសម្រួល

| | |
|---|---|
| លោក ស សុផាណាក់ | ប្រធានសម្របសម្រួលផ្នែកបច្ចេកវិទ្យាសម្រាប់ការអប់រំ |



# អំពីអង្គការ ខេប

ខេប គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធ នៅក្នុងប្រទេសកម្ពុជា។ ខេបបានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលនៅក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ កម្មវិធីអាហារូបករណ៍សម្រាប់សិស្សនៅសាកលវិទ្យាល័យ និងកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ។ ចំនួនកុមារទទួលផលផ្ទាល់មានជាង ១៥០០០០នាក់ និងគ្រូបង្រៀនជាច្រើនរយនាក់ដែលបង្រៀននៅជាង ៤០០សាលាក្នុង១៣រាជធានី-ខេត្ត។

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ខេប គឺផ្តល់លទ្ធភាពដល់កុមារ និងយុវជននូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្តានុពលរបស់ពួកគេតាមរយៈទទួលបានការអប់រំល្អ។

## បេសកកម្ម

បេសកកម្មរបស់អង្គការ ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់អំណាចដល់កុមារ និងយុវជនងាយរងគ្រោះក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រឌិតថ្មី។

## គុណតម្លៃ

- ការផ្តល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្តីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី ឬច្នៃប្រឌិតថ្មី
- តម្លាភាព
- ជឿជាក់

**ការអភិវឌ្ឍមនុស្ស ប្រកបដោយសេចក្តីថ្លៃថ្នូរ!**

# មុខងារគម្រោងរបស់អង្គការ ខេប តាមផ្នែកបច្ចេកទេសក្នុងឆ្នាំ២០២១

**គម្រោងខេបឆ្នាំ ២០២១**

| | ពាក្យបំព្រួញ | ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ | ICT សម្រាប់ការអប់រំ | ការអភិវឌ្ឍគ្រូបង្រៀន | កម្មវិធីអប់រំបរិយាប័ន្ន | កម្មវិធីអំណានថ្នាក់ដំបូង | កម្មវិធីមត្តេយ្យសិក្សា | រចនាបថហេដ្ឋារចនាសម្ព័ន្ធ | ការអភិវឌ្ឍបណ្ណាល័យ | កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព | កម្មវិធីឆ្លើយតបនឹងវិស័យអប់រំក្នុងបរិបទកូវីដ១៩ |
|---|---|---|---|---|---|---|---|---|---|---|---|
| ១. គម្រោង សៀវភៅសម្រាប់កម្ពុជា | BfC | | | | | | | | ✓ | | |
| ២. កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ-១៩ | CERRP | | ✓ | ✓ | ✓ | ✓ | | | | | ✓ |
| ៣. គម្រោងអប់រំកុមារី | GEI | | | | ✓ | | | | | ✓ | ✓ |
| ៤. គម្រោង វាយតម្លៃ-**GPE3** (តេស្ត **EGRA**) | GPE3-PE | | | | | ✓ | | | | | |
| ៥. គម្រោង កុមារកម្ពុជារីករាយ | HCC | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៦. គម្រោង សកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា | KYLA | | | | ✓ | | | | | ✓ | |
| ៧. គម្រោង អប់រំបំណិនជីវិតសម្រាប់កុមារី | LSLAG | | | | ✓ | | | | | ✓ | |
| ៨. មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | NGPRC | ✓ | ✓ | ✓ | | | | | | | ✓ |
| ៩. គម្រោង សាលារៀនជំនាន់ថ្មី (កម្រិតបឋម) | NGS-P | ✓ | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ | ✓ |
| ១០. គម្រោង សាលារៀនជំនាន់ថ្មី (កម្រិតមធ្យម) | NGS-S | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| ១១. គម្រោង សាលារៀនជំនាន់ថ្មី/ស្វាយរៀង | NGS-SR | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| ១២. គម្រោង ពន្លកចំណេះ (ស្រាវជ្រាវប្រឹក្សាគរុកោសល្យ) | PC | | | ✓ | | | | | | | |
| ១៣. គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ | REACH IV | | | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ |
| ១៤. គម្រោង លើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា | SEEK | | | ✓ | ✓ | | | | | ✓ | ✓ |
| ១៥. គម្រោង វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ | TRAC III | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | ✓ |
| ១៦. គម្រោង អភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ២ | USE-SDP2 | | ✓ | ✓ | | | | ✓ | ✓ | ✓ | |
| ១៧. គម្រោង សហគ្រិនវ័យក្មេង | YEP | | | | ✓ | | | | | ✓ | ✓ |
| ១៨. គម្រោង សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម | Co-SAVED | | ✓ | ✓ | ✓ | | ✓ | ✓ | ✓ | ✓ | |
| ១៩. គម្រោង ងាយស្រួលរៀន | E2L | | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| **សរុបគម្រោងកំពុងដំណើរការក្នុងផ្នែកនីមួយៗ** | | ៤ | ៧ | ១១ | ១២ | ៦ | ៣ | ៦ | ៨ | ១១ | ១២ |

# ចំនួនអ្នកទទួលផលផ្ទាល់





| | | |
|---|---|---|
| ១២០៨៣១ | ២៨០៦ | ១៩៩៦ |
| សិស្សានុសិស្ស | គ្រូបង្រៀន/នាយក | ភាគីពាក់ព័ន្ធ |

# ចំនួនសាលាគោលដៅ




១១០ មធ្យមសិក្សា

១៧២ បឋមសិក្សា




៤២ មត្តេយ្យសិក្សា

១ ឧត្តមសិក្សា

# ម្ចាស់ជំនួយអង្គការ ខេប ក្នុងឆ្នាំ២០២១

unicef for every child

GPE Transforming Education

GVC

We World

This project is co-funded by the European Union

EDUCATE A CHILD — A programme of education above all

Aide et Action — Changing the world through Education

THE PHOENIX FOUNDATION

ChildFund Cambodia

ADB

The Asia Foundation — Improving Lives, Expanding Opportunities

OXFAM

lotus outreach INTERNATIONAL

lotus outreach SOCIETY CANADA

USAID FROM THE AMERICAN PEOPLE

pact building local promise.

Oaktree

UNESCO

FFF | Franks Family Foundation

Gap Inc.

P.A.C.E. Gap Inc. Advancing Women to Advance the World

# តំបន់គោលដៅអនុវត្តគម្រោងក្នុងឆ្នាំ២០២១ របស់អង្គការ ខេប មានចំនួន ១៣ រាជធានី-ខេត្ត



អនុវិស័យទី

១

# ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ

“បង្កើតសាលារៀនរដ្ឋជាមួយនឹងស្តង់ដាសាលារៀនឯកជន”

# Charter School Development

*Creating Public Schools with Private School Standards*



# ការគ្រប់គ្រងសាលារៀន

កម្មវិធីសាលារៀនជំនាន់ថ្មី (NGS) បានរៀបចំសិក្ខាសាលាស្តីពី "**ការគ្រប់គ្រងសាលារៀន**" នៅសាលប្រជុំសាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន កំពង់ចាម ដោយមានសិក្ខាកាមចំនួន៣៥នាក់មកពីសាលារៀនគោលដៅទាំង១០។ សិក្ខាសាលានេះមានគោលបំណងណែនាំទូទៅសម្រាប់អនុវត្តការគ្រប់គ្រងតាមសាលារៀន ដោយផ្តល់កិច្ចតែងការដល់អ្នកសម្របសម្រួល និងបណ្តុះបណ្តាលពីគោលការណ៍គ្រប់គ្រងតាមសាលារៀនទៅដល់អ្នកពាក់ព័ន្ធទាំងអស់នៅតាមសាលារៀនខ្លួន។

សិក្ខាកាមទាំងអស់បានលើកយកអំពីបញ្ហាប្រឈមដែលបានកើតឡើងនៅសាលារៀនរបស់ខ្លួមមកពិភាក្សា និងឆ្លុះបញ្ចាំង ជាមួយសៀវភៅរបស់ក្រសួង។

សិក្ខាសាលានេះបានប្រើប្រាស់សៀវភៅ "អនុវត្តការគ្រប់គ្រងតាមសាលា" របស់ក្រសួងអប់រំ យុវជន និងកីឡា ហើយបានផ្តល់ឱកាសដល់សិក្ខាកាមទាំងអស់ពិភាក្សាក្រុមស្វែងរកចំណុចខ្វះខាត និងផ្លាស់ប្តូរនូវគំនិតថ្មីសម្រាប់អភិវឌ្ឍការគ្រប់គ្រងសាលារៀន៕



សកម្មភាពសិក្ខាកាមកំពុងពិភាក្សាក្រុមលើការអភិវឌ្ឍការគ្រប់គ្រងសាលារៀន។

# អង្គវិបស្សនាកម្មវិធីសាលារៀនជំនាន់ថ្មី



លោក សៅ វណ្ណា ប្រធានប្រតិបត្តិអង្គការ ខេប អំឡុងពេលបើកកម្មវិធីអង្គវិបស្សនា។

កាលពីថ្ងៃទី៨ ដល់ទី១១ ខែកុម្ភៈ ឆ្នាំ២០២២ កម្មវិធីសាលារៀនជំនាន់ថ្មីដែលទទួលបានហិរញ្ញប្បទានពីក្រសួងអប់រំយុវជន និងកីឡាបានរៀបចំអង្គវិបស្សនានៅរមណីយដ្ឋាន ហ្សូប កោះរ៉ុងសន្លឹមនៅខេត្តព្រះសីហនុ ដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីសកម្មភាពកម្មវិធីដែលបានអនុវត្តកន្លងមកទាក់ទងទៅនឹងវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយ។ សមាសភាពអ្នកចូលរួមសរុបមានចំនួន២៧នាក់ ជាបុគ្គលិកគម្រោង និងអ្នកពាក់ព័ន្ធ។

អង្គវិបស្សនានេះ មានគោលបំណង៖ ១-ពង្រឹងនិរន្តរភាព ស្វ័យប្រតិបត្តិការរបស់សាលារៀននីមួយៗ និងការត្រៀមខ្លួនសម្រាប់ការពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មី។ ២-ពង្រឹងសមត្ថភាពបច្ចេកទេសបុគ្គលិក និងមន្ត្រីសាលារៀន និង៣-រៀបចំផែនការអភិវឌ្ឍន៍ និងវិនិយោគរបស់កម្មវិធីសាលារៀនជំនាន់ថ្មី ឆ្នាំ២០២២។

លោក **ប៊ិន ចាន់នី** ប្រធានក្រុមមជ្ឈសិក្សាបានមានប្រសាសន៍ថា "***ការរៀបចំកម្មវិធីអង្គវិបស្សនានេះឡើង ដើម្បីផ្តល់ឱកាសឱ្យបុគ្គលិកបានចែករំលែកបទពិសោធន៍ បញ្ហាប្រឈមដែលបានជួបប្រទះ និងជជែកពិភាក្សាគ្នាដើម្បីស្វែងរកដំណោះស្រាយ និងធ្វើយ៉ាងណាឱ្យការអនុវត្តកម្មវិធីទទួលបានដំណើរការល្អប្រកបដោយនិរន្តរភាព***"។

លោក **សៅ វណ្ណា** ប្រធានប្រតិបត្តិអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា បានមានប្រសាសន៍ថា "*កម្មវិធីសាលារៀនជំនាន់ថ្មីបានកែប្រែវិស័យអប់រំនៅកម្ពុជាមានការអភិវឌ្ឍ និងអាចឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងក្នុងសម័យឌីជីថលនេះ។ ដោយសារតែការអនុវត្តកម្មវិធីសម្រេចបានសមិទ្ធផលល្អៗជាច្រើនគួរឱ្យកត់សម្គាល់ ដូច្នេះហើយ ក្រសួងអប់រំ យុវជន និងកីឡា បន្តផ្តល់ថវិកាសម្រាប់អនុវត្តកម្មវិធី និងពង្រីកសាលារៀនជំនាន់ថ្មីបន្តទៀតនៅឆ្នាំ២០២៣*"។

ជាលទ្ធផល បុគ្គលិកទាំងអស់របស់កម្មវិធីសាលារៀនជំនាន់ថ្មីបានបង្ហាញពីសមិទ្ធផល ផលសម្រេចបាន បញ្ហាប្រឈម និងដំណោះស្រាយនៅតាមផ្នែកនីមួយៗរបស់ខ្លួនទៅកាន់ក្រុមធំដើម្បីស្វែងរកមតិគាំទ្របន្ថែមព្រមទាំងពង្រឹងការអនុវត្តសកម្មភាពឱ្យមានការរីកចម្រើនបន្តទៀត។ ការរៀបចំអង្គវិបស្សនាជាសកម្មភាពត្រួតពិនិត្យ តាមដាន និងវាយតម្លៃបច្ចុប្បន្នភាពគម្រោង៕

# កិច្ចប្រជុំក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ កម្មវិធីសាលារៀនជំនាន់ថ្មី



*ឯកឧត្តម ឡោ ឆវណ្ណា អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ និងជាប្រធានក្រុមប្រឹក្សាភិបាលសាលារៀនជំនាន់ថ្មីកំពុងពិនិត្យមើលរបាយការណ៍របស់កម្មវិធីសាលារៀនជំនាន់ថ្មី។*

កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ កម្មវិធីសាលារៀនជំនាន់ថ្មីបានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលថ្នាក់ជាតិស្តីពីការធ្វើរបាយការណ៍វឌ្ឍនភាពសាលារៀនជំនាន់ថ្មី និងការវាយតម្លៃសាលារៀនជំនាន់ថ្មីសម្រាប់ឆ្នាំសិក្សា ២០២១-២០២២ ក្រោមអធិបតីភាពឯកឧត្តម ឡោ ឆវណ្ណា អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ និងជាប្រធានក្រុមប្រឹក្សាភិបាលសាលារៀនជំនាន់ថ្មី ព្រមទាំងសមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីកម្មវិធីសរុបចំនួន ១៣នាក់។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសាលារៀនជំនាន់ថ្មី មានគោលបំណង៖

- បង្ហាញរបាយការណ៍វឌ្ឍនភាព និងលទ្ធផលសកម្មភាពសាលារៀនជំនាន់ថ្មីទាំងមធ្យមសិក្សា និងបឋមសិក្សានៅឆ្នាំ២០២១។

-បង្ហាញរបាយការណ៍វឌ្ឍនភាពអំពីកម្មវិធីនៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យសាលារៀនជំនាន់ថ្មី (NGPRC) ឆ្នាំ២០២១ និងលទ្ធផលនៃការអនុវត្តកម្មវិធី។

ឯកឧត្តម ឡោ ឆវណ្ណា ប្រធានក្រុមប្រឹក្សាភិបាលបានមានប្រសាសន៍ថា "***លទ្ធផលដែលសម្រេចបានរបស់កម្មវិធីសាលារៀនជំនាន់ថ្មីបានមកពីការខិតខំប្រឹងប្រែងរបស់មន្ត្រីកម្មវិធីទាំងអស់គ្នា បើទោះបីជាកម្មវិធីទទួលផលប៉ះពាល់ពីវីរុសកូវីត-១៩ក៏ដោយ តែកម្មវិធីបានដោះស្រាយបញ្ហាទាន់ពេលវេលា និងបានបន្តអនុវត្តសកម្មភាពរបស់ខ្លួនក្នុងសាលារៀនគោលដៅនីមួយៗបានយ៉ាងល្អ***"។ លោកបានបន្តទៀតថា ក្នុងក្របខ័ណ្ឌនៃកម្មវិធីគឺមានការចាប់ផ្តើម និងមានការបញ្ចប់ តែអ្វីដែលសំខាន់មុននឹងបញ្ចប់កម្មវិធី គឺយើងត្រូវប្រមូលឯកសារទុកសម្រាប់ប្រើប្រាស់នៅក្នុងអង្គភាព។

ជាលទ្ធផល សាលារៀនជំនាន់ថ្មីចំនួន៦ ទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាព ដូចជា វិទ្យាល័យព្រះស៊ីសុវត្ថិ វិទ្យាល័យហ៊ុន សែនកំពង់ចាម វិទ្យាល័យគោកព្រីង វិទ្យាល័យ ព្រែកលៀប វិទ្យាល័យសម្តេចអគ្គមហាធម្មពោធិសាល ជាស៊ីម ព្រែកអញ្ចាញ និងសាលាបឋមសិក្សាស្វាយព្រហូត ព្រមទាំងរៀបចំផែនការបន្ត ដើម្បីកែលម្អចំណុចខ្វះខាតក្នុងការអនុវត្តកម្មវិធី។ ការរៀបចំកិច្ចប្រជុំនេះឡើងក៏ជាសកម្មភាពមួយដ៏សំខាន់ដើម្បីធ្វើការផ្ទៀងផ្ទាត់ ត្រួតពិនិត្យសារឡើងវិញនូវរាល់ផែនការសកម្មភាពទាំងអស់ និងសម្រាប់ធ្វើបច្ចុប្បន្នភាពវឌ្ឍនភាពរបស់គម្រោង៕



*សកម្មភាពមន្ត្រីកម្មវិធីសាលារៀនជំនាន់ថ្មីក្នុងអំឡុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលថ្នាក់ជាតិសម្រាប់បង្ហាញរបាយការណ៍ និងសមិទ្ធផលរបស់កម្មវិធី។*

អនុវិស័យទី ២

# បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ការអប់រំ

“បច្ចេកវិទ្យានឹងមិនអាចជំនួសគ្រូដ៏ឆ្នើមៗបានទេ ប៉ុន្តែគ្រូឆ្នើមៗក៏មិនអាចអត់បច្ចេកវិទ្យាសម្រាប់បរិវត្តកម្មបានដែរ”

# Information and Communication Technology (ICT) in Education

*Technology will never replace great teachers, but in the hands of great teachers, it's transformational*



# ការចុះប្រមូលទិន្នន័យពីថាប់ភ្លែតនៅតាមសាលារៀនគោលដៅ

កាលពីថ្ងៃទី១-២ ខែកុម្ភៈ ឆ្នាំ២០២២ គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRAC III) បានរៀបចំវគ្គសិក្សាសាលាតម្រង់ទិសពីការធ្វើតេស្តអំណានថ្នាក់ដំបូង (EGRA) ដែលមានសិក្ខាកាមចូលរួមសរុបចំនួន១៧នាក់ រួមមាន៖ អ្នកស្ម័គ្រចិត្តជានិស្សិតមកពីសកលវិទ្យាល័យនានាក្នុងខេត្តកំពង់ចាម មន្ត្រីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត។



សកម្មភាពអ្នកស្ម័គ្រចិត្តកំពុងអនុវត្តមុនចុះប្រមូលទិន្នន័យនៅតាមសាលារៀនគោលដៅ។

គោលបំណងនៃការធ្វើតេស្ត EGRA នេះ គឺមិនមែនដើម្បីវាយតម្លៃសាលា ឬគ្រូបង្រៀននោះឡើយ ប៉ុន្តែវាគឺជាការវាស់សមត្ថភាពអានរបស់សិស្សថ្នាក់ដំបូង (ពីថ្នាក់ទី១ដល់ទី៣) ក្រោយពីកុមារខកខានទៅសាលារៀនស្ទើតែពេញមួយឆ្នាំដោយសារការរីករាលដាលនៃជំងឺកូវីត-១៩ ហើយពួកគេទទួលបានការសិក្សាពីចម្ងាយ និងតាមបណ្តុំខ្ចងផ្ទះនាឆ្នាំសិក្សាកន្លងទៅ (២០២០-២១) ក្រោមការខិតខំប្រឹងប្រែងពីក្រសួងអប់រំ យុវជន និងកីឡា និងមានអន្តរាគមន៍បន្ថែមពីគម្រោងរបស់អង្គការ ខេប ។

ជាលទ្ធផល សិក្ខាកាមទទួលបានចំណេះដឹង និងនីតិវិធីក្នុងការធ្វើតេស្តយ៉ាងច្បាស់លាស់ បន្ទាប់មកពួកគេនឹងត្រូវចុះទៅប្រមូលទិន្នន័យនៅតាមសាលារៀនគោលដៅរបស់គម្រោងចំនួន១៨ ដែលកំពុងប្រតិបត្តិផែនការសកម្មភាពនៅក្នុងទាំងពីរគឺ៖ ខេត្តត្បូងឃ្មុំ និងកំពង់ចាម៕

# សុសវែរកម្មវិធីអប់រំអំណានសម្រាប់ការពង្រឹងអំណានដល់កុមារ

អង្គការ ខេប ជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា ហើយបានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលតាំងពីសាលាមត្តេយ្យសិក្សា រហូតដល់កម្រិតឧត្តមសិក្សា។

ការពង្រឹងអំណានថ្នាក់ដំបូង គឺជាសកម្មភាពដ៏សំខាន់ដែលគម្រោងជាច្រើនបានយកចិត្តទុកដើម្បីជួយអន្តរាគមន៍ដល់កុមារបង្កើនកម្រិតនៃការអាន និងសរសេរ (ថ្នាក់ទី១ ទី២ និងថ្នាក់ទី៣)។ ដូច្នេះ អង្គការ ខេប បានអភិវឌ្ឍកម្មវិធីសុសវែរជាច្រើនដើម្បីជាជំនួយជួយដល់កុមារអភិវឌ្ឍសមត្ថភាពលើជំនាញអាន និងសរសេរ ជាពិសេសពួកគេអាចរៀនសូត្របានគ្រប់ទីកន្លែង។ កម្មវិធីទាំងអស់នោះរួមមាន៖

**១-កម្មវិធីសៀវភៅឆ្លាត** គឺជាកម្មវិធីមួយដើម្បីពង្រឹងពិន្ទុអំណានរបស់កុមារកម្ពុជានៅថ្នាក់ទី២ និងថ្នាក់ទី៣។ កម្មវិធីសៀវភៅឆ្លាតត្រូវបានបង្កើតឡើងជាសៀវភៅអេឡិចត្រូនិច ដោយប្រើប្រាស់អត្ថបទសៀវភៅភាសាខ្មែរថ្នាក់ទី២ និងថ្នាក់ទី៣ រួចបំលែងទៅជាបីកម្រិត។ វាអនុញ្ញាតឱ្យកុមារអានពីមួយកម្រិតទៅមួយកម្រិតតាមសមត្ថភាពរបស់ពួកគេជាមួយនឹងលក្ខណៈទាក់ទាញជាច្រើន ដូចជា រូបភាពមានចលនា សំឡេង និងលំហាត់ឌីជីថល ដើម្បីលើកកម្ពស់ការរៀនសូត្រ ជួយកុមារចេះពាក្យថ្មីៗ និងមានការវាយតម្លៃមួយប្រកបដោយភាពច្បាស់។

**២-កម្មវិធីអានខ្មែរ** គឺជាល្បែងសិក្សាសម្រាប់ពង្រឹងអំណានដល់សិស្សថ្នាក់ទី១ និងទី២ ផ្អែកលើបំណិនអំណានចំនួន៥គឺ ការស្គាល់សូរ ការស្គាល់តួអក្សរ ការអានស្ទាត់ ការអានពាក្យ និងការអានដើម្បីយល់ន័យ។ អ្វីគួរឱ្យចាប់អារម្មណ៍ រាល់ខ្លឹមសារនៅក្នុងកម្មវិធីអានខ្មែរទាំងអស់ត្រូវបានដកស្រង់ចេញពីសៀវភៅសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីនេះមានចំនួន៣១មេរៀន ក្នុងនោះមានលំហាត់ចំនួន៣ក្នុងមេរៀននីមួយៗ ដូចជា (១) អនុវត្តសំឡេងតួអក្សរ និងការបញ្ចេញសំឡេង (២) អនុវត្តកិច្ចការពីមុនៗ រួមមាន៖ ស្វែងរកសូរតួអក្សរ ផ្គូផ្គងតួអក្សរ និងពាក្យ និង (៣) ស្តាប់រឿងខ្លីៗដែលមានពាក្យ និងអក្សរដែលបានរៀនរួច។

**៣-កម្មវិធីសរសេរខ្មែរ** គឺជាកម្មវិធីសម្រាប់កុមាររៀនសរសេរអក្សរខ្មែរ។ សរសេរខ្មែរមានចាប់ពីថ្នាក់ទី១ដល់ថ្នាក់ទី៣ ដែលអនុញ្ញាតឱ្យកុមារអាចរៀនសរសេរបាន៤វិធីទៅតាមមេរៀននីមួយៗ ដូចជា របៀបសរសេរ សរសេរតាមមើល សរសេរតាមស្តាប់ និងសរសេរតាមរូបភាព។

ជារួម ដើម្បីជួយអន្តរាគមន៍លើសមត្ថភាពអំណានរបស់កុមារ អាណាព្យាបាលសិស្សអាចធ្វើការទាញយកកម្មវិធីទាំងនេះដាក់នៅលើទូរសព្ទ Android សម្រាប់បង្រៀនកុមារបានគ្រប់ទីកន្លែង៕






អនុវិស័យទី ៣

# ការអភិវឌ្ឍគ្រូបង្រៀន

"គ្រូដែលល្អមិនមែនគ្រាន់តែជាអ្នកប្រាប់ ជាអ្នកពន្យល់ និងបង្ហាញនោះទេ តែជាអ្នកជំរុញលើកទឹកចិត្តសិស្ស"

## Teacher Development

*"The mediocre teacher tells. The good teacher explains. The superior teacher demonstrates. The great teacher inspires."*



# ការប្រើប្រាស់សៀវភៅស្តង់ដាអំណានឱ្យមានប្រសិទ្ធភាព

គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ( TRAC III ) បានរៀបចំសិក្ខាសាលាស្តីពី **ការប្រើប្រាស់សៀវភៅស្តង់ដាអំណាន** ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី៥-៦ ខែមករា ឆ្នាំ២០២២ នៅសាលាគរុកោសល្យ និងវិក្រឹតការ ខេត្តកំពង់ចាម ដោយមានសិក្ខាកាមចូលរួមសរុបមានចំនួន៥០នាក់ មកពីសាលារៀនគោលដៅចំនួន១៨នៅក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។ សិក្ខាសាលានេះមានគោលបំណងផ្តល់ឱ្យសិក្ខាកាមបានស្វែងយល់បន្ថែមអំពីការប្រើប្រាស់សៀវភៅស្តង់ដាអំណានឱ្យត្រូវតាមគោលដៅប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់ក្នុងការបង្រៀនប្រចាំថ្ងៃនៅតាមសាលាគោលដៅនីមួយៗ ព្រមទាំងបង្ហាញអំពីបច្ចុប្បន្នភាពរបស់គម្រោងត្រាក់៣។

លោក **ឡាង ប៉ាង** ជានាយកសាលាបឋមសិក្សា ហ៊ុន សែន ជៀស បានមានប្រសាសន៍ថា "*សិក្ខាសាលានេះបានបញ្ជ្រាបនូវខ្លឹមសារសំខាន់ៗសម្រាប់គាំទ្រដល់ការបង្រៀន និងរៀន។ ម្យ៉ាងវិញទៀត ខ្ញុំបានទទួលចំណេះដឹងថ្មីៗទាក់ទងការប្រើប្រាស់ទំព័រហ្វេសប៊ុក ការបែងចែកម៉ោងសិក្សា ស្តង់ដាអំណានដែលមានអត្ថប្រយោជន៍សម្រាប់យកទៅអនុវត្តនៅតាមសាលារៀន*"។

លោកស្រី **រិន ណារី** ជាគ្រូបង្រៀនថ្នាក់ទី៣កនៃសាលាបឋមសិក្សា គ្រញូង បានមានប្រសាសន៍ថា"*ខ្ញុំទទួលបានចំណេះដឹងជាច្រើនដូចជា ដឹងពីរបៀបលេងល្បែងសិក្សានៅក្នុងមេរៀននីមួយៗ ការប្រើប្រាស់សៀវភៅស្តង់ដាអំណាន ដឹងពីដំណើរការធ្វើតេស្តតាមដំណាក់កាល និងចេះបែងចែកម៉ោងសម្រាប់ការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព។ សិក្ខាសាលានេះពិតជាល្អ និងមានប្រយោជន៍ណាស់ចំពោះខ្ញុំក្នុងការបង្រៀន និងរៀនជាមួយបច្ចេកទេសថ្មីៗ រួមផ្សំជាមួយវិធីសាស្ត្របង្រៀនល្អៗ*"។

លោកគ្រូអ្នកគ្រូបានដឹងពីវឌ្ឍនភាពគម្រោង លទ្ធផលតេស្តដំណាក់កាល សូចនាករដែលគម្រោងកំពុងអនុវត្តន៍ ការប្រើប្រាស់ទំព័រហ្វេសប៊ុក ( Facebook page ) ពង្រឹងតួនាទី និងភារកិច្ចគ្រូបង្វឹកអំណានឡើងវិញ រំលឹកពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងរៀបចំកាលវិភាគសម្រាប់ឆ្នាំសិក្សាថ្មី ២០២១-២០២២ ឱ្យល្អជាងមុន៕



*លោកគ្រូអ្នកគ្រូពិភាក្សាគ្នាពីតួនាទីគ្រូបង្វឹកដើម្បីជួយសិស្សដែលធ្លាក់តេស្តដំណាក់កាលនៅក្នុងសាលារៀនគោលដៅ។*

# ការរំឭកថ្នាក់ពន្លឿនការសិក្សាថ្នាក់ទី១




*សកម្មភាពលោកគ្រូអ្នកគ្រូចូលរួមវគ្គសិក្ខាសាលាតាមប្រព័ន្ធអនឡាញ។*

គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំវគ្គសិក្ខាសាលាស្តីពី ការរំឭកថ្នាក់ពន្លឿនការសិក្សាថ្នាក់ទី១ ដល់ថ្នាក់ទី៦ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ តាមរយៈប្រព័ន្ធអនឡាញ(Zoomនិង Google Meet)។ សមាសភាពអ្នកចូលរួមសរុបមានចំនួន១៤៩នាក់ ដូចជា នាយកនាយករង និងលោកគ្រូអ្នកគ្រូ មកពីសាលារៀនគោលដៅចំនួន៣០សាលាក្នុងខេត្តចំនួន៤ រួមមាន៖ ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តរតនគិរី និងខេត្តសៀមរាប។

វគ្គសិក្ខាសាលានេះ មានគោលបំណងជួយសម្រួលដល់លោកគ្រូអ្នកគ្រូ ដើម្បីយកទៅបង្រៀនសិស្សានុសិស្ស ដែលខកខានមិនបានទទួលសេវាអប់រំពេញលេញដោយសារការគំរាមកំហែងពីជំងឺកូវីដ-១៩ ដើម្បីកសាងមូលដ្ឋានគ្រឹះឱ្យរឹងមាំសម្រាប់សិស្សឈានទៅកាន់កម្រិតថ្នាក់ថ្មី។

លោក **ថា ស្រស់** ជាគ្រូបង្រៀនកិច្ចសន្យានៅសាលាបឋមសិក្សាក្រញូងសែនជ័យ បានមានប្រសាសន៍ថា ***"ចំណេះដឹងដែលខ្ញុំទទួលបានពីវគ្គសិក្ខាសាលា គឺដឹងពីរបៀបនៃការប្រើប្រាស់សៀវភៅពន្លឿនការសិក្សាកាន់តែច្បាស់លាស់ជាងមុន ដើម្បីជួយបង្រៀនដល់សិស្សានុសិស្សឱ្យរៀនទាន់តាមកម្មវិធីសិក្សា ក៏ដូចជាបានជួយពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូបង្រៀនកិច្ចសន្យាពាក់ព័ន្ធទាក់ទងទៅនិងការបង្រៀន និងរៀនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់"***។

លោកគ្រូអ្នកគ្រូបានឆ្លុះបញ្ចាំងពីការអនុវត្តនាពេលកន្លងមកក្នុងការប្រើប្រាស់សៀវភៅពន្លឿនការសិក្សា ចែករំលែកបទពិសោធន៍ បញ្ហាប្រឈម និងដំណោះស្រាយទៅវិញទៅមក ដើម្បីចូលរួមចំណែកលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ក៏ដូចជាជួយកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សានៅតាមសាលារៀនគោលដៅ។ គម្រោង HCC បានយកចិត្តខ្លាំងបំផុតលើការបំប៉នសមត្ថភាពគ្រូបង្រៀន៕

# ការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែមដើម្បីពង្រឹងការបង្រៀនគ្រូ

កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំវគ្គសិក្ខាសាលារំឭកឡើងវិញស្តីពី ការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែម ដែលប្រព្រឹត្តទៅតាមប្រព័ន្ធអនឡាញ (Zoom, Google Meet) និងមានសិក្ខាកាមចូលរួមសរុបចំនួន ១៤០នាក់ (ស្រី៥២នាក់) មកពីសាលារៀនគោលដៅចំនួន១១ក្នុងខេត្តចំនួន៤ រួមមាន៖ ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តរតនគិរី និងខេត្តកំពង់ចាម។

សិក្ខាសាលានេះមានគោលបំណងពង្រឹងសមត្ថភាពសិក្ខាកាមលើការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែមសម្រាប់ថ្នាក់ទី២ ដល់ទី៦ ឱ្យបានត្រឹមត្រូវប្រកបដោយគុណភាព និងមានប្រសិទ្ធភាពក្នុងការបង្រៀន និងរៀននៅតាមសាលារៀន។

សិក្ខាកាមបានចែករំលែកបទពិសោធន៍ ជជែកពិភាក្សាស្វែងរកដំណោះស្រាយលើបញ្ហាដែលបានជួបប្រទះក្នុងការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែម។

លោកគ្រូអ្នកគ្រូបានដកស្រង់យកចំណុចល្អៗទាំងអស់ទៅអនុវត្តនៅតាមសាលាគោលដៅរៀងៗខ្លួន ធ្វើយ៉ាងណាបង្កឱ្យសិស្សបានសិក្សាប្រកបដោយការរីកចម្រើន និងទទួលលទ្ធផលកាន់តែល្អឡើងបន្ថែមទៀត៕




*ផ្ទាំងស្លាយមួយនៅក្នុងបទបង្ហាញរបស់គម្រោងត្រាកពលើកញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែម។*

# ការប្រើប្រាស់ថវិកាអភិវឌ្ឍន៍សាលារៀនឱ្យមានប្រសិទ្ធភាព



*នាយក និងនាយិកាចំនួន១៦នាក់ មកពីសាលាបឋមសិក្សាចំនួន ១៥ ក្នុងស្រុកកំពង់ត្រាច និងស្រុកទឹកឈូ ដែលបានចូលរួមវគ្គបណ្តុះបណ្តាល។*

កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ គម្រោងសម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនិងការគាំទ្រសំឡេង ដើម្បីសមធម៌សង្គម (CO-SAVED) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ថវិកាអភិវឌ្ឍន៍សាលារៀនទៅកាន់នាយកសាលា ត្រូវបានរៀបចំឡើងនៅក្នុងខេត្តកំពត ដោយមានអ្នកចូលរួមសរុបចំនួន១៦នាក់ រួមមាន៖ នាយក និងនាយិកាដែលមកពីសាលាបឋមសិក្សាចំនួន ១៥ក្នុងស្រុកកំពង់ត្រាច និងស្រុកទឹកឈូ។

វគ្គបណ្តុះបណ្តាលនេះមានគោលបំណងតម្រង់ទិសនាយក/នាយិកាអំពីការប្រើប្រាស់ថវិកាអភិវឌ្ឍន៍សាលារៀនប្រកបដោយប្រសិទ្ធភាព។

លោក **សុខ ហេង** ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកទឹកឈូបានមានប្រសាសន៍ថា"***សាលារៀននីមួយៗមានការអភិវឌ្ឍផែនការសម្រាប់ឆ្នាំសិក្សាថ្មី ២០២១-២០២២ បន្ទាប់ពីទទួលបានវគ្គបណ្តុះបណ្តាលទាក់ទងនឹងទៅសាលាកុមារមេត្រី និងសូមឱ្យនាយក/នាយិកាប្រើប្រាស់ថវិកាឱ្យមានប្រសិទ្ធភាពសម្រាប់ផ្លាស់ប្តូរ ក៏ដូចជាកែប្រែបរិស្ថានសាលារៀនឱ្យមានការអភិវឌ្ឍន៍ដើម្បីធ្វើឱ្យកុមារទទួលការអប់រំប្រកបដោយប្រសិទ្ធភាព និងមានប្រសិទ្ធផល***"។

លោកនាយក/នាយិកាបានរៀនសូត្រ និងយល់ដឹងកាន់តែច្បាស់ពីការប្រើប្រាស់ថវិកាអភិវឌ្ឍសាលារៀន ជាពិសេសទាក់ទងទៅនឹងកម្មវិធីសាលាកុមារមេត្រី ដែលមានបរិយាកាសសប្បាយរីករាយសម្រាប់កុមារក្នុងការសិក្សា៕

---

# ការបណ្តុះបណ្តាលគ្រូបង្គោលកម្មវិធីបំណិនជីវិត Gap Inc. P.A.C.E.

គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG) បានរៀបចំសិក្ខាសាលាស្តីពី ការបណ្តុះបណ្តាលគ្រូបង្គោលកម្មវិធីបំណិនជីវិត Gap Inc. P.A.C.E. តាមរយៈប្រព័ន្ធអនឡាញ (Zoom) ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៦-១៧ ខែកុម្ភៈ ឆ្នាំ២០២២ ដោយមានការចូលរួមពីតំណាងនាយកដ្ឋាន-មន្ទីរអប់រំ យុវជន និងកីឡា ទាំង២៥រាជធានី-ខេត្ត។




សកម្មភាពលោកគ្រូអ្នកគ្រូថតជុំគ្នាបន្ទាប់ពីវគ្គសិក្ខាសាលាត្រូវបានបញ្ចប់។

សិក្ខាសាលាមានគោលបំណងឱ្យសិក្ខាកាម៖ ១-យល់ដឹងអំពីគម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG)។ ២-យល់ដឹងពីបញ្ញត្តិ និយមន័យការអប់រំបំណិនជីវិត និងយេនឌ័រ ដើម្បីបញ្ជ្រាបនូវការយល់ដឹងដល់សិស្សក្នុងកម្មវិធីសិក្សាគែស(P.A.C.E)។ ៣-យល់ដឹងពីភាពប្រែប្រួលរបស់មនុស្សវ័យជំទង់ និងមនុស្សធំ/ពេញវ័យ។ ៤-យល់ដឹងអំពីការបណ្តុះបណ្តាលបែបចូលរួម វិធីសាស្ត្របណ្តុះបណ្តាល និងជំនាញសម្របសម្រួល។ ៥-យល់ដឹងពីវិធីសាស្ត្រ និងការប្រើប្រាស់សៀវភៅទាំង៨ម៉ូឌុល និងសកម្មភាពពិនិត្យតាមដាន និងវាយតម្លៃក្នុងគម្រោង។

លោក **អ៊ុល រុន** ទី (**អានបន្តទំព័រ ១២...**)

(...តពីទំព័រ ១១)ប្រឹក្សាជាតិជាន់ខ្ពស់របស់អង្គការ ខេប បានមានប្រសាសន៍ថា "*សិស្សនឹងមានជំនាញទុនជាច្រើនសម្រាប់ដឹកនាំជីវិតរបស់ពួកគេនៅក្នុងវិស័យការងារ បើទោះបីជាសិស្សបានរៀនសៀវភៅកម្មវិធីសិក្សា Gap Inc. P.A.C.E. បានតែបីក្បាលក៏ដោយ ពីព្រោះវាបានបណ្តុះគំនិតក្មេងស្រីឱ្យយល់ដឹងអំពីខ្លួនរបស់ពួកគេ ដឹងពីសមភាពយេនឌ័រ មានទំនាក់ទំនងល្អ ក្លាហាន និងអាចក្លាយជាបុគ្គលដែលអាចរស់នៅពឹងពាក់លើខ្លួនឯងបាន ជាពិសេសអាចនឹងក្លាយជាជនគំរូដល់ក្មេងស្រីដទៃទៀតផងដែរ*"។

លោក **រ័ត្ន សារ៉ា** ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈបានមានប្រសាសន៍ថា "*បំណិនជីវិត គឺបំណិនមួយជួយបណ្តុះការគិតដល់សិស្សឱ្យមានទស្សនៈវិស័យវែងឆ្ងាយជំរុញ និងលើកទឹកចិត្តសិស្សឱ្យគិតអំពីបំណងប្រាថ្នា និងបានបង្រៀនសិស្សឱ្យស្គាល់អំពីខ្លួនឯង ក៏ដូចជាត្រៀមខ្លួនរួចជាស្រេចសម្រាប់ចាប់យកឱកាសការងារនាពេលខាងមុខ ហើយជំនាញទន់ដែលពាក់ព័ន្ធនឹងការប្រែប្រួលឥរិយាបថ ការទំនាក់ទំនង ការគិតពិចារណា និងការធ្វើការងារជាក្រុមនេះ វាជាជំនាញដែលមិនងាយស្រួលនោះទេ វាទាមទារឱ្យមានការអនុវត្តជាប្រចាំសម្រាប់ឱ្យសិស្សបានចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គម ការពារបរិស្ថាន ស្គាល់ពីគុណតម្លៃនៃការសិក្សារៀនសូត្រ និងធ្វើឱ្យពួកគេមានការប្រែប្រួលឥរិយាបថក្នុងការសិក្សា*"។

លោក **ទុំ ទីតូណា** ប្រធានគម្រោង អប់រំបំណិនជីវិតសម្រាប់កុមារី( LSLAG )បានមានប្រសាសន៍ថា "*កម្មវិធីបំណិនជីវិត Gap Inc. P.A.C.E. គឺជាការដាក់ទុនលើជំនាញថ្មីដើម្បីអនាគត ដែលជាកម្មវិធីបំណិនជីវិតមូលដ្ឋានថ្មីមួយសម្រាប់ក្មេងស្រីអាយុ១១ឆ្នាំដល់១៧ឆ្នាំ ដែលមានគោលបំណងដើម្បីកសាងបំណិន និងប្រសិទ្ធភាពដល់កុមារី ដើម្បីឱ្យមានទំនុកចិត្ត សមត្ថភាពធ្វើការសម្រេចចិត្ត និងចេះធ្វើផែនការសម្រាប់អនាគតរបស់ពួកគេ*" ។

ជាលទ្ធផល អ្នកចូលរួមបានស្គាល់ពីកម្មវិធីបំណិនជីវិត Gap Inc. P.A.C.E. ដែលកម្មវិធីនេះត្រូវបានបែងចែកជា២ក្រុមអាយុ គឺ៖ ទី១ កម្មវិធីសិក្សាសម្រាប់ក្មេងស្រីទំនង់ដែលមានអាយុចាប់ពី១១ដល់១៣ឆ្នាំ (មានប្អូនម៉ូឌុល) និងទី២ កម្មវិធីសិក្សាសម្រាប់ក្មេងស្រីពេញវ័យ ដែលមានអាយុចាប់ពី១៤ដល់១៧ឆ្នាំ (មានប្អូនម៉ូឌុល) យល់ដឹងពីសកម្មភាពគម្រោងដែលកំពុងប្រតិបត្តិនៅក្នុងតំបន់គោលដៅ និងកញ្ចប់ថវិកាសម្រាប់ការអនុវត្តកម្មវិធី ៕




*លោក រ័ត្ន សារ៉ា ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ បានចូលរួមផ្តល់ជាទស្សនអំពីបំណិនជីវិតក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាលតាមរយៈប្រព័ន្ធអនឡាញ។*

# ការប្រមូលកុមារក្រៅសាលារៀន និងការគូសផែនទីខ្នងផ្ទះ

កាលពីថ្ងៃទី២២ ដល់ ទី២៤ ខែកុម្ភៈ ឆ្នាំ ២០២២ គម្រោងងាយស្រួលរៀន (E2L) បានរៀបចំវគ្គបណ្តុះបណ្តាលនាយកសាលាបឋមសិក្សា និងគណៈកម្មការគ្រប់គ្រងសាលារៀនស្តីពី ការប្រមូលកុមារក្រៅសាលារៀន ការគូសផែនទីខ្នងផ្ទះ គណៈកម្មការអាហារូបករណ៍ និងប្រព័ន្ធរំលឹកទុកជាមុនដែលរៀបចំឡើងនៅសាលប្រជុំនៃសាកលវិទ្យាល័យក្រចេះ។ វគ្គបណ្តុះបណ្តាលនេះមានសមាសភាពអ្នកចូលរួមសរុបចំនួន៣៥នាក់ រួមមាន៖ នាយក នាយិកា គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀនដែលមកពីសាលារៀនគោលដៅចំនួន៧ក្នុងខេត្តក្រចេះ។ កម្មវិធីងាយស្រួលរៀននៅក្នុងខេត្តក្រចេះទទួលបានជំនួយហិរញ្ញប្បទានពីអង្គការឆាលហ្វានប្រទេសកូរ៉េខាងត្បូង និងប្រតិបត្តិដោយអង្គការ ខេប ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបាន និងការរក្សាក្មេងស្រីនិងក្មេងប្រុសដែលគ្រប់អាយុចូលសាលាបឋមសិក្សា រួមទាំង កុមារនិងមាននិងគ្មានលទ្ធភាព ជាពិសេសកុមារពិការភាពនៅក្នុងសាលាបឋមសិក្សាគោលដៅ។

កម្មវិធីបណ្តុះបណ្តាលនេះមានគោលបំណង៖ **១**-ប្រមូលកុមារគ្រប់អាយុបានចូលរៀនទាំងអស់គ្នា។ **២**-ការរៀបចំផែនទីខ្នងផ្ទះ ដើម្បីរកឱ្យឃើញកុមារដល់វ័យសិក្សាត្រូវចូលរៀន ស្វែងរកកុមារមិនទាន់បានចុះឈ្មោះចូលរៀន ឬកុមារជួបការលំបាកគ្រប់ប្រភេទ។ **៣**-ជ្រើសរើសសិស្សអាហារូបករណ៍គ្រួសារក្រីក្រ គ្រួសារជួបការលំបាកពិតប្រាកដ និងគ្រួសារងាយរងគ្រោះ។ **៤**-ផ្សព្វផ្សាយការអនុវត្តកម្មវិធីវិន័យតាមបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាពខ្ពស់។ **៥**-ផ្សារភ្ជាប់ការអនុវត្តជាក់ស្តែងរបស់គ្រូនៅតាមមូលដ្ឋានជាមួយសិស្សអំពីអាកប្បកិរិយា ពាក្យសំដីកាន់តែមានភាពល្អប្រសើរ។

សិក្ខាកាមនឹងទទួលបានចំណេះដឹងសំខាន់ៗមួយចំនួនដូចខាងក្រោម៖
**១**-កំណត់បានស្ថិតិកុមារតាមភូមិសិក្សាគ្រប់អាយុចូលរៀន។ **២**-កំណត់បានកុមារជួបការលំបាក ងាយរងគ្រោះ កុមារក្រីក្រ និងគ្រួសារកុមារប្រើអំពើហិង្សា។ **៣**-កំណត់បានពីទណ្ឌកម្មរាងកាយ និងផ្នែកស្មារតីជាអ្វី។ **៤**-កំណត់បានពីផលវិបាកនៃទណ្ឌកម្មរាងកាយ និងផ្នែកស្មារតី។ **៥**-ឆ្លុះបញ្ចាំង និងការស្វែងយល់អំពីសារៈសំខាន់ជនគំរូ។ **៦**-គ្រប់គ្រងអារម្មណ៍ និងរំងាប់កំហឹងបាន។ **៧**-អនុវត្តការដាក់វិន័យបែបវិជ្ជមានជំនួសដោយការដាក់ទណ្ឌកម្មរាងកាយ និងផ្នែកស្មារតី។ **៨**-សរសេរគោលការណ៍សម្រាប់ថ្នាក់រៀនជាមួយសិស្ស និងលើកទឹកចិត្តសិស្សឱ្យមានអាកប្បកិរិយាល្អ។

លោកនាយក នាយិកា គណៈកម្មការគ្រប់គ្រងសាលារៀន សហគមន៍ និងអ្នកពាក់ព័ន្ធបានចូលរួមសហការគ្នា ដើម្បីប្រមូលកុមារក្រៅសាលាបានចូលរៀនពេញលេញ យល់ដឹងពីនិតិវិធីក្នុងការជ្រើសរើសសិស្សអាហារូបករណ៍ និងវិន័យបែបវិជ្ជមានរវាងគ្រូបង្រៀន និងសិស្ស ព្រមទាំងបានរៀបចំផែនទីសម្រាប់ឆ្នាំសិក្សាថ្មី៕




*សកម្មភាពលោកគ្រូអ្នកគ្រូពិភាក្សាគ្នាលើកត្តាដែលធ្វើឱ្យប៉ះពាល់ដល់ការសិក្សារបស់កុមារនៅតាមតំបន់ដាច់ស្រយាល។*

# ការពង្រឹងសមត្ថភាពគ្រូលើការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែម



លោកគ្រូអ្នកគ្រូតាមសាលារៀនគោលដៅចូលរួមយ៉ាងសកម្មជាមួយគម្រោង។

កាលពីថ្ងៃទី១០ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំវគ្គសិក្ខាសាលាស្តីពី "ការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែម" ដែលធ្វើឡើងតាមប្រព័ន្ធអនឡាញ (Zoom និង Google Meet) ដោយមានអ្នកចូលរួមសរុបមានចំនួន២៥៣នាក់ រួមមាន៖ មន្ត្រីការិយាល័យបឋមនៃមន្ទីរ អប់រំ យុវជន និងកីឡាខេត្ត មន្ត្រីការិយាល័យ អប់រំ យុវជន និង កីឡាស្រុក នាយក នាយិកា និងលោកគ្រូអ្នកគ្រូដែលមកពីសាលារៀនគោលដៅទាំងអស់ក្នុងខេត្តសៀមរាប ខេត្តក្រចេះ ខេត្តត្បូងឃ្មុំ ខេត្តរតនគិរី និងខេត្តកំពង់ចាម។ សិក្ខាសាលានេះធ្វើឡើងដើម្បីពង្រឹងសមត្ថភាពសិក្ខាកាមលើការប្រើប្រាស់កញ្ចប់ឯកសារបង្រៀនបន្ថែម ថ្នាក់ទី២ដល់ទី៦ក្នុងបរិបទជំងឺកូវីដ-១៩ ឱ្យចំគោលដៅប្រកបដោយគុណភាព និងមានប្រសិទ្ធភាពក្នុងការបង្រៀន និងរៀន និងផ្តល់វគ្គបណ្តុះបណ្តាលអំពីនិតិវិធីនៃការរៀនបណ្តុំតាមខ្នងផ្ទះក្នុងភូមិដល់លោកគ្រូ អ្នកគ្រូ ដើម្បីយកទៅអនុវត្តបន្តនៅតាមសាលាគោលដៅរបស់ខ្លួន។

សិក្ខាកាមទទួលបានចំណេះដឹងមួយចំនួនទាក់ទងទៅនឹងការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែម ដូចជា ការបង្កើតសកម្មភាពថ្មីក្នុងការបង្រៀន និងរៀន របៀបធ្វើតេស្តរបៀបបំប៉នបន្ថែមដល់សិស្សរៀនយឺត តួនាទីរបស់អាណាព្យាបាល និងអ្នកពាក់ព័ន្ធ យល់ដឹងពីរបៀបកំណត់ពិន្ទុលើសន្លឹកកិច្ចការសិស្ស និងរបៀបនៃការចុះបញ្ជីឯកសារសិស្សដើម្បីងាយស្រួលក្នុងការតាមដានលទ្ធផល និងជំរុញសិស្សរៀនខ្សោយឱ្យទទួលបានលទ្ធផលល្អប្រសើរ។

ជាលទ្ធផល សិក្ខាកាមបានយល់ដឹង និងអាចប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែមក្នុងការបង្រៀន និងរៀន ដើម្បីជួយអន្តរាគមន៍ដល់សិស្សរៀនយឺតឱ្យទាន់កម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា៕

# គណៈកម្មការសុខភាពតាមសាលារៀន



តំណាងមន្ត្រីអង្គការឆាលហ្វាន ចូលរួមក្នុងវគ្គសិក្ខាសាលាស្តីពីគណៈកម្មការសុខភាពតាមសាលារៀន។

កាលពីថ្ងៃទី១៦-១៧ ខែមីនា ឆ្នាំ២០២២ គម្រោងងាយស្រួលរៀន (E2L) ទទួលបានហិរញ្ញប្បទានពីអង្គការឆាលហ្វានកូរ៉េខាងត្បូង តាមរយៈអង្គការឆាលហ្វាន កម្ពុជា បានរៀបចំសិក្ខាសាលាស្តីពី គណៈកម្មការសុខភាពតាមសាលារៀន ដែលធ្វើឡើងនៅសាលាបឋមសិក្សាភូមិថ្មី និងមានសិក្ខាកាមចូលរួមសរុបចំនួន៣៦នាក់ រួមមាន៖ នាយក/នាយិកា គ្រូដឹកនាំទីប្រឹក្សាកុមារី គ្រូដឹកនាំក្រុមប្រឹក្សាកុមារ និងគណៈកម្មការគ្រប់គ្រងសាលារៀន។

វគ្គសិក្ខាសាលាមានគោលបំណងផ្តល់ឱ្យសិក្ខាកាមបាន៖ ១-យល់ដឹងពីសារៈសំខាន់អាហារូបត្ថម្ភ ស្គាល់ពីតួនាទីអាហារទាំង៣ក្រុម និងអនាម័យសម្រាប់កុមារក៏ដូចជាគ្រូបង្រៀន បានសិក្សាស្វែងយល់ពីការការពារពីការរីករាលដាលជំងឺកូវីដ-១៩។ ២-អប់រំកុមារតាមសាលារៀន អនុវត្តនូវ ៣កុំ៣ការពារ និងរក្សាគម្លាតសុវត្ថិភាព។ ៣-យល់ច្បាស់ពីការគ្រប់គ្រងអាហារប្រកបដោយសុវត្ថិភាព និងអនាម័យក្នុងការចម្អិន។

គណៈកម្មការសុខភាពតាមសាលារៀនគោលដៅនីមួយៗនឹងធ្វើការផ្សព្វផ្សាយពីគោលការណ៍សុខភាពដល់លោកគ្រូអ្នកគ្រូ អ្នកលក់ដូរក្នុងបរិវេណសាលា សហគមន៍ មាតាបិតា អាណាព្យាបាលសិស្ស និងសិស្សានុសិស្សឱ្យហូបស្អាត ផឹកស្អាត និងរស់នៅស្អាតជាប្រចាំដើម្បីថែទាំសុខភាព។ ក្រៅពីនេះ គម្រោងក៏បានធ្វើការពង្រឹងបរិស្ថានថ្នាក់រៀន និងការផ្តល់សម្ភារបង្រៀន និងរៀន ដល់សាលារៀនគោលដៅផងដែរ៕

# ការពង្រឹងតួនាទី ទីប្រឹក្សាកុមារី



លោកគ្រូអ្នកគ្រូពិភាក្សាគ្នាអំពីតួនាទីគ្រូដឹកនាំក្រុមប្រឹក្សាកុមារ និងទីប្រឹក្សាកុមារី។

កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ គម្រោងងាយស្រួលរៀន (E2L) ទទួលបានហិរញ្ញប្បទានពីអង្គការឆាលហ្វានកូរ៉េខាងត្បូង បានរៀបចំវគ្គទម្រង់ទិសមួយស្តីពី **ទីប្រឹក្សាកុមារី**ដែលបានធ្វើឡើងនៅសាលាបឋមសិក្សាស្រែស្បូវ ដោយមានអ្នកចូលរួមសរុបចំនួន១៦នាក់ ជាគ្រូទីប្រឹក្សាកុមារី និងគ្រូដឹកនាំក្រុមប្រឹក្សាកុមារទាំងប្រាំពីរសាលារៀនក្នុងស្រុកសំបូរ។

វគ្គទម្រង់ទិសមានគោលបំណង៖ ១-ដើម្បីស្វែងយល់អំពីទិដ្ឋភាពទូទៅ ដែលពាក់ព័ន្ធទៅនឹងកម្មវិធីទីប្រឹក្សាកុមារីរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានដាក់ឱ្យដំណើរការអនុវត្តនៅតាមសាលារៀនសាធារណៈទូទាំងប្រទេស។ ២-សិក្សាស្វែងយល់អំពីដំណើរការរៀបចំរចនាសម្ព័ន្ធរបស់ទីប្រឹក្សាកុមារីនៅតាមសាលាបឋមសិក្សា រួមទាំងរចនាសម្ព័ន្ធនានាដែលពាក់ព័ន្ធជាមួយកម្មវិធីទីប្រឹក្សាកុមារី។ ៣-ពង្រឹងការអនុវត្តកម្មវិធីទីប្រឹក្សាកុមារីនៅតាមសាលា ដើម្បីបង្កើនស្មារតីចូលរួមទប់ស្កាត់ការបោះបង់ការសិក្សា ការចូលរួមប្រឹក្សាយោបល់ល្អៗដល់កុមារ និងការចូលរួមក្នុងការជួយបង្កើតនូវប្រព័ន្ធសុវត្ថិភាពនានាដល់កុមារនៅតាមសាលារៀន។

ក្នុងវគ្គតម្រង់ទិសនេះ សិក្ខាកាមបានជជែកពិភាក្សាគ្នាអំពីមូលហេតុដែលបណ្តាលឱ្យមានកម្មវិធីទីប្រឹក្សាកុមារីតាមសាលារៀន សារៈប្រយោជន៍អំពីមិត្តអប់រំមិត្ត តួនាទី និងលក្ខណៈសម្បត្តិរបស់គ្រូទីប្រឹក្សាកុមារី និងគ្រូដឹកនាំក្រុមប្រឹក្សាកុមារ។

លោកគ្រូអ្នកគ្រូបានយល់ដឹងពីតួនាទី និងភារកិច្ចព្រមទាំងគាំទ្រដល់ដំណើរការកម្មវិធីទីប្រឹក្សាកុមារី និងមិត្តអប់រំមិត្តឱ្យមាននៅតាមសាលារៀនគោលដៅនីមួយៗ។ គម្រោងលើកកម្ពស់ការអប់រំតាមរយៈការអភិវឌ្ឍ និងអនុវត្តវិធីសាស្ត្រសាលាកុមារមេត្រី៕

# វគ្គបណ្តុះបណ្តាលសមត្ថភាពរបស់បណ្ណារក្ស

កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ គម្រោងងាយស្រួលរៀន (E2L) ដែលគាំទ្រហិរញ្ញប្បទានដោយអង្គការឆាលហ្វាន បានរៀបចំវគ្គទម្រង់ទិសមួយស្តីពី តួនាទី និងភារកិច្ចបណ្ណារក្ស ដែលបានធ្វើឡើងនៅសាលាបឋមសិក្សាស្រែស្បូវ។ សមាសភាពអ្នកចូលរួមសរុបមានចំនួន១៥នាក់ ជាបណ្ណារក្សនាយក និងនាយិកា ដែលមកពីសាលារៀនគោលដៅទាំងអស់របស់គម្រោង។



សកម្មភាពលោកគ្រូអ្នកគ្រូចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបណ្ណារក្ស។

វគ្គនេះមានគោលបំណងពង្រឹងសមត្ថភាពបណ្ណារក្សលើការគ្រប់គ្រង រៀបចំបញ្ជីឬសៀវភៅ និងឯកសារនៅក្នុងបណ្ណាល័យតាមសាលានីមួយៗឱ្យមានសណ្តាប់ធ្នាប់សម្រាប់លោកគ្រូអ្នកគ្រូ សិស្ស សហគមន៍ចូលអាន សិក្សាស្រាវជ្រាវប្រកបដោយផាសុកភាព។

លោកគ្រូអ្នកគ្រូទទួលបានចំណេះដឹងល្អៗមួយចំនួនទាក់ទងនឹងលក្ខណៈសម្បត្តិជាបណ្ណារក្ស ការតុបតែងលម្អ និងថែទាំក៏ដូចជាវិធីសាស្ត្រក្នុងការគ្រប់គ្រងបណ្ណាល័យដើម្បីដឹកនាំបណ្ណាល័យឱ្យបើកដំណើរការបានជាប្រចាំសម្រាប់សិស្ស សហគមន៍ព្រមទាំងគ្រូបង្រៀនចូលមកអាន និងស្រាវជ្រាវស្វែងរកព័ត៌មានបន្ថែម។

លោកគ្រូអ្នកគ្រូជាបណ្ណារក្សបានដឹងច្បាស់ពីតួនាទី និងភារកិច្ចក្នុងការគ្រប់គ្រងបណ្ណាល័យឱ្យមានដំណើរការល្អ។ ពួកគាត់បានបង្ហាញការតាំងចិត្តយកមេរៀនទាំងនេះទៅរៀបចំដឹកនាំបណ្ណាល័យឱ្យបានប្រសើរ៕

# ការគ្រប់គ្រងបណ្ណាល័យ


សកម្មភាពលោកគ្រូអ្នកគ្រូពិភាក្សាគ្នាលើការគ្រប់គ្រងបណ្ណាល័យ។

កាលពីថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០២២ គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម (CO-SAVED) បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ការគ្រប់គ្រងបណ្ណាល័យ ជូនដល់សាលារៀនគោលដៅចំនួន៤៦ ដែលធ្វើឡើងនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត ដោយមានអ្នកចូលរួមសរុបចំនួន ៦៦នាក់ ដែលជានាយក នាយិកា និងបណ្ណារក្ស។

វគ្គបណ្តុះបណ្តាលនេះមានគោលបំណងផ្តល់ឱ្យសិក្ខាកាមទទួលបានបច្ចេកទេស ពីរបៀបផ្តល់សេវាកម្ម និងគ្រប់គ្រងបណ្ណាល័យ ក៏ដូចជាពង្រឹងការរៀបចំបណ្ណាល័យឱ្យមានសោភ័ណភាពល្អប្រសើរ។

លោក **សាន ស៊ិត** មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាស្រុកទឹកឈូ បានមានប្រសាសន៍ថា "*បណ្ណាល័យជាប្រភពស្រាវជ្រាវ និងជាកន្លែងសម្រាប់បណ្តុះទម្លាប់អានដល់កុមារ ហើយបណ្ណារក្សជាកម្លាំងចលករដ៏សំខាន់ក្នុងការជំរុញឱ្យបណ្ណាល័យមានដំណើរ ដើម្បីទាក់ទាញសិស្សឱ្យស្រឡាញ់ និងចាប់អារម្មណ៍ព័ត៌មានក្នុងបណ្ណាល័យ*"។

សិក្ខាកាមចូលរួមទាំងអស់បានរៀនសូត្រ និងយល់ដឹងច្បាស់ពីទំនួលខុសត្រូវរបស់បណ្ណារក្ស ការគ្រប់គ្រងរដ្ឋបាលក្នុងបណ្ណាល័យ ការរៀបចំផែនការអភិវឌ្ឍបណ្ណាល័យ និងជំរុញសិស្សានុសិស្សក្នុងការអានជាប្រចាំ មិនថានៅផ្ទះ ឬនៅសាលារៀននោះទេ។ CO-SAVED គឺជាគម្រោងសម្ព័ន្ធដែលដឹកនាំប្រតិបត្តិដោយអង្គការប្រមាណជា១៤ រយៈពេល ៤ឆ្នាំក្នុងខេត្តកំពត៕

# កិច្ចប្រជុំឆ្លុះបញ្ចាំងស្តីពីគ្រូបង្វឹកអំណាន

កាលពីសប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២២ គម្រោងពង្រឹងការអប់រំ និងលទ្ធភាពទទួលបានការងារតាមរយៈការចូលរួមរបស់សហគមន៍ (BMZ) បានរៀបចំការប្រជុំឆ្លុះបញ្ចាំងស្តីពី គ្រូបង្វឹកអំណាន នៅក្នុងទីតាំងផ្សេងៗគ្នាក្នុងខេត្តគោលដៅចំនួន៣ រួមមាន៖ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងស្វាយរៀង។ សមាសភាពចូលរួមសរុបចំនួន៦៧នាក់ ដែលជាតំណាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក នាយក/នាយិកា និងគ្រូបង្វឹកអំណាន។

គោលបំណងនៃអង្គប្រជុំឆ្លុះបញ្ចាំងនេះដើម្បី៖ **១**-បង្កើនការយល់ដឹងបន្ថែមស្តីពីតួនាទី និងទំនួលខុសត្រូវរបស់គ្រូបង្វឹកអំណាន លើសកម្មភាពអានរបស់កុមារ ដែលទាក់ទងទៅនឹងសៀវភៅស្តង់ដាអំណាន ឧបករណ៍វាយតម្លៃតេស្តអំណាន និងប្រព័ន្ធរំលឹកទុកជាមុន (EWS) និង **២**-បង្ហាញការប្រើប្រាស់ល្បែងសិក្សាដល់គ្រូបង្វឹកអំណាន និងនាយកសម្រាប់ជួយអន្តរាគមន៍ដល់សិស្សដែលធ្លាក់ក្នុងការធ្វើតេស្តដំណាក់។


សកម្មភាពលោកគ្រូអ្នកគ្រូបង្វឹកអំណានពិភាក្សាគ្នាដើម្បីជួយអន្តរាគមន៍ដល់សិស្សរៀនយឺត។

កិច្ចប្រជុំនេះបានលើកការពិភាក្សាគ្នាអំពីចំណុចសំខាន់ៗទាក់ទងនឹងសមិទ្ធិផល បញ្ហាប្រឈមក្នុងការធ្វើតេស្តស្តង់ដាអំណានថ្នាក់ទី១ ទី២ និងទី៣ ពង្រឹងលើការអនុវត្តតេស្តដំណាក់កាល និងការធ្វើតេស្តផ្ទាល់មាត់ ក៏ដូចជាកម្មវិធីបង្រៀន ពង្រឹងលើការអានរៀបចំផែនការបន្ទាប់ និងទទួលមតិត្រឡប់ពីអាណាព្យាបាលសិស្សក្នុងសហគមន៍លើការរៀនសូត្ររបស់កុមារនៅតាមសាលារៀននីមួយៗ។

អ្នកចូលរួមបានយល់ដឹងបានច្បាស់អំពីតួនាទី និងការទទួលខុសត្រូវ ព្រមទាំងគាំទ្រសកម្មភាពគម្រោងដើម្បីជួយកុមារឱ្យទទួលបានការអប់រំប្រកបដោយគុណភាព មានប្រសិទ្ធភាព និងប្រសិទ្ធផល។ កិច្ចប្រជុំនេះក៏ជាសូចនាករសម្រាប់គ្រូបង្វឹកអំណានដែរ៕

# វគ្គតម្រង់ទិសស្តីពី តួនាទី និងភារកិច្ចគ្រូស្ម័គ្រចិត្ត

គម្រោងងាយស្រួលរៀន (E2L) ទទួលហិរញ្ញប្បទានពីអង្គការឆាលហ្វាន កម្ពុជា បានរៀបចំវគ្គតម្រង់ទិសមួយស្តីពី តួនាទី និងភារកិច្ចគ្រូស្ម័គ្រចិត្តនៅសាកលវិទ្យាល័យក្រចេះ។ អ្នកចូលរួមសរុបមានចំនួន១០៤នាក់ ដែលជានាយក នាយិកា គ្រូស្ម័គ្រចិត្ត និងគ្រូបង្រៀន។

សិក្ខាសាលានេះ មានគោលបំណង៖

១-ដើម្បីស្វែងយល់អំពីទិដ្ឋភាពទូទៅ ដែលពាក់ព័ន្ធទៅនឹងកម្មវិធីដូចជា ការរៀបចំសន្លឹកកិច្ចការ ការវាយតម្លៃសមត្ថភាពសិស្សតាមដំណាក់កាល និងការវាយតម្លៃសិស្សសរុប។

២-ពង្រឹងសមត្ថភាពគ្រូក្នុងការកំណត់កម្រិតសមត្ថភាពសិស្ស និងរៀបចំផែនការបង្រៀនជួយសិស្សរៀនយឺតឱ្យបានទាន់ពេលវេលា។

លោក **នូ ស៊ីណាត** ប្រធានគម្រោងងាយស្រួលរៀន បានមានប្រសាសន៍ថា "***ដើម្បីដឹងពីកម្រិតសមត្ថភាពសិស្ស គ្រូបង្រៀនត្រូវធ្វើការវាយតម្លៃសមត្ថភាពសិស្សជាប្រចាំនៅពេលកំពុងបង្រៀន និងរៀនចប់មេរៀនមួយ ដើម្បីស្ទាបស្ទង់ការយល់ដឹងរបស់សិស្ស ក៏ដូចជាស្វែងរកចំណុចខ្សោយរបស់សិស្សដើម្បីជួយពួកគេឱ្យទាន់ពេលវេលា តាមរយៈការបំប៉នបន្ថែមដល់សិស្សរៀនយឺត***"។

សិក្ខាកាមនឹងរៀបចំផែនការប្រចាំខែសម្រាប់បង្រៀន និងរៀន យល់ដឹងកាន់តែច្បាស់ពីរបៀបនៃការវាយតម្លៃ ការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែម និងវិធីសាស្ត្រតេស្តសិស្ស ដើម្បីជួយអន្តរាគមន៍ដល់សិស្សរៀនយឺតឱ្យទទួលបានលទ្ធផលល្អប្រសើរក្នុងមេរៀនបន្ទាប់។ គម្រោង E2L ធ្វើការបណ្តុះបណ្តាលនាយក នាយិកា និងគ្រូនៅសាលារៀនគោលដៅអំពីវិធីសាស្ត្របង្រៀនតាមកម្មវិធីសាលាកុមារមេត្រី ជាពិសេសលើកកម្ពស់ជំនាញលេខ និងអក្ខរកម្មរបស់កុមារ៕



*លោក នូ ស៊ីណាត ប្រធានគម្រោងងាយស្រួលរៀន (E2L) ខេត្តព្រៃវែង កំពុងធ្វើបទបង្ហាញទាក់ទងទៅនឹងតួនាទី និងភារកិច្ចគ្រូស្ម័គ្រចិត្ត។*

# ហេតុអ្វីត្រូវធ្វើការកសាងផែនការអភិវឌ្ឍសាលារៀន ?

កាលពីថ្ងៃទី២៧-៣០ ខែមីនា ឆ្នាំ ២០២២ គម្រោងងាយស្រួលរៀន (E2L) ខេត្តក្រចេះក្រោមជំនួយហិរញ្ញប្បទានពីអង្គការឆាលហ្វាន កូរ៉េអាងត្បូង បានរៀបចំវគ្គសិក្ខាសាលាស្តីពី ការកសាងផែនការអភិវឌ្ឍសាលារៀននៅតាមសាលារៀនគោលដៅនីមួយៗរបស់គម្រោង ដោយមានសមាសភាពចូលរួមសរុបចំនួន១៤៣នាក់ ដែលជាគណៈគ្រប់គ្រងសាលារៀន នាយក នាយិកា គ្រូបង្រៀន សហគមន៍ ក្រុមប្រឹក្សាកុមារ និងមន្ត្រីរបស់អង្គការឆាលហ្វាន កម្ពុជា។

សិក្ខាសាលានេះមានគោលបំណងពង្រឹងលើការប្រើប្រាស់ថវិកាពីគ្រប់ប្រភពឱ្យមានតម្លាភាពសម្រាប់អភិវឌ្ឍន៍ផែនការសាលារៀនក្នុងឆ្នាំសិក្សាថ្មី ២០២២-២០២៣។

សិក្ខាកាមបានយល់ដឹងពីសកម្មភាពជាច្រើនរបស់គម្រោងកំពុងប្រតិបត្តិក្នុងសាលារៀនគោលដៅ ចំណេះដឹងល្អៗដើម្បីប្រែក្លាយសាលាធម្មតាទៅជាសាលាកុមារមេត្រី យល់ដឹងពីរបៀបវិភាគដើមឈើបញ្ហា និងនិតិវិធីមួយចំនួននៃការប្រើប្រាស់កញ្ចប់ថវិកាដែលគម្រោងបានផ្តល់ជូនសាលារៀនគោលដៅសម្រាប់អភិវឌ្ឍន៍។

សិក្ខាកាមនឹងរៀបចំផែនការអភិវឌ្ឍសាលារៀនដើម្បីកែលម្អបរិស្ថានឱ្យមានសោភ័ណភាព និងបរិយាកាសរីករាយសម្រាប់សិស្សានុសិស្សចូលសិក្សា៕



*លោក មុំ ឡៃ ប្រធានគម្រោងងាយស្រួលរៀន (E2L) ក្រចេះ បានធ្វើបទបង្ហាញពីផែនការអភិវឌ្ឍសាលារៀន។*

# ហេតុអ្វីបានជាការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែមសំខាន់ក្នុងការសិក្សា?



*សកម្មភាពវគ្គបណ្តុះបណ្តាលនៅខេត្តរតនគិរីពី ការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែម។*

កាលពីថ្ងៃទី៥-៦ ខែមេសា ឆ្នាំ២០២២ គម្រោងលើកកម្ពស់គុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា (EQUAL) ក្រោមជំនួយហិរញ្ញប្បទានពីអង្គការផ្លែនកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការប្រើប្រាស់សៀវភៅកញ្ចប់ឯកសារបំប៉នបន្ថែម នៅវិទ្យាល័យបរកែវ មានសមាសភាពចូលរួមសរុបចំនួន៣៧នាក់ ដែលជាមន្ត្រីមន្ទីរការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ស្រុក នាយក នាយិកា និងលោកគ្រូ/អ្នកគ្រូមកពីសាលារៀនគោលដៅចំនួន១៥ក្នុងខេត្តរតនគិរី។

វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងលើកកម្ពស់កុមារនៅក្រៅសាលា និងកុមារជនជាតិភាគតិចក្នុងខេត្តរតនគិរី ឱ្យមានឱកាសបំពេញសិទ្ធិក្នុងការអប់រំនៅបឋមសិក្សា និងបន្តទៅអនុវិទ្យាល័យដោយរលូនតាមរយៈការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងផ្លាស់ប្តូរបែបយេនឌ័រ។

កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ទី២ ដល់ទី៦ ក្នុងគោលបំណងផ្តល់ឱកាស ជួយជំរុញ និងលើកទឹកចិត្តសិស្សបានសិក្សារៀនសូត្រ ផ្សារភ្ជាប់ជាមួយសកម្មភាពល្បែងសិក្សាព្រមទាំងសកម្មភាពដទៃទៀតពីកញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមភាសាខ្មែរ និងគណិតវិទ្យា ដោយបង្កើតឡើងនូវបរិយាកាសសិក្សាសប្បាយរីករាយដល់កុមារ បានចូលរួមយ៉ាងសកម្មក្នុងថ្នាក់រៀន និងទទួលបានលទ្ធផលល្អប្រកបដោយជោគជ័យ។

លោកគ្រូអ្នកគ្រូបានយល់ដឹងពីការប្រើប្រាស់សៀវភៅកញ្ចប់ឯកសារបំប៉នបន្ថែម ដូចជា របៀបធ្វើតេស្តភាសាខ្មែរ និងគណិតវិទ្យាពីថ្នាក់ទី២ ដល់ទី៦ យល់ពីការរៀបចំកិច្ចតែងការបង្រៀន និងរៀន ក៏ដូចជាកម្មវិធីសិក្សាសម្រាប់ការបង្រៀន។ ម្យ៉ាងទៀត លោកគ្រូអ្នកគ្រូក៏បានចែករំលែកបទពិសោធន៍បង្រៀន និងរៀនទៅវិញទៅមកក្នុងការពង្រឹងវិធីសាស្ត្របង្រៀនសិស្សឱ្យកាន់តែល្អប្រសើរឡើង។

លោកគ្រូអ្នកគ្រូនឹងរៀបចំផែនការបង្រៀន ដោយយករៀងរាល់ថ្ងៃព្រហស្បតិ៍ បង្រៀនសៀវភៅកញ្ចប់ឯកសារបំប៉នបន្ថែម ដល់សិស្សរហូតដល់ចប់មេរៀន។ គម្រោង EQUAL ធ្វើឱ្យកុមារផ្លាស់ប្តូរការលំបាក៕

# កិច្ចប្រជុំស្តីពីកម្មវិធីសិក្សា ICT Computational Thinking



*សកម្មភាពប្រជុំពីការអភិវឌ្ឍកម្មវិធីសិក្សាផ្នែក ICT ដោយមានការចូលរួមពីខាង InSTEDD។*

កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ កម្មវិធីសាលារៀនជំនាន់ថ្មី និងអង្គការ InSTEDD បានសហការគ្នារៀបចំកិច្ចប្រជុំមួយទាក់ទងនឹងការអភិវឌ្ឍ "**កម្មវិធីសិក្សា** ICT Computational Thinking" នៅសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រែកលៀប ដោយមានសមាសភាពចូលរួមប្រមាណជា៣០នាក់ ជាលោកគ្រូអ្នកគ្រូផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICT) ប្រចាំនៅសាលារៀនជំនាន់ថ្មីចំនួន៦ ដូចជា វិទ្យាល័យព្រះស៊ីសុវត្ថិ វិទ្យាល័យ ហ៊ុន សែន កំពង់ចាម វិទ្យាល័យព្រែកលៀប វិទ្យាល័យសម្តេច ជា ស៊ីម ព្រែកអញ្ចាញ វិទ្យាល័យ ហ៊ុន សែន ពាមជីកង និងអនុវិទ្យាល័យគោកព្រីង។

កិច្ចប្រជុំនេះធ្វើឡើងផ្តោតសំខាន់លើការរៀបចំកម្មវិធីសិក្សា ICT Computational Thinking ការសរសេរកូដ និងការដោះស្រាយបញ្ហាប្រឈមផ្សេងៗសម្រាប់ធ្វើឱ្យសាលារៀនជំនាន់ថ្មីដំណើរការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាពក្នុងសម័យឌីជីថល ព្រោះបច្ចេកវិទ្យាដើរតួនាទីយ៉ាងសំខាន់ក្នុងការរស់នៅប្រចាំថ្ងៃ។

លោកគ្រូអ្នកគ្រូ ICT របស់សាលារៀនជំនាន់ថ្មីទាំងអស់នឹងធ្វើការជាមួយគ្នាយ៉ាងជិតស្និតនាពេលខាងមុខ ដើម្បីពង្រឹងការបង្រៀន និងរៀនកាន់តែល្អប្រសើរលើផ្នែកICT ដោយមានការគាំទ្របច្ចេកទេសពីខាងក្រុមការងារខាង InSTEDD និងអង្គការ ខេប៕

# ប្រព័ន្ធគ្រប់គ្រងទិន្នន័យកុមារ និងយុវជនប្រឈមនឹងហានិភ័យ




*លោក សេង សុធី អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកោះកុង ចូលរួមជាធិបតីភាពក្នុងវគ្គបណ្តុះបណ្តាល។*

កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនិងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម (CO-SAVED) បានរៀបចំវគ្គបណ្តុះបណ្តាលមួយស្តីពី ប្រព័ន្ធគ្រប់គ្រងទិន្នន័យកុមារ និងយុវជនប្រឈមនឹងហានិភ័យ ជូនដល់សាលារៀនគោលដៅចំនួន៤៩ ដែលធ្វើឡើងនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកោះកុង។ នៅក្នុងវគ្គនេះ មានសមាសភាពចូលរួមសរុបចំនួន៥៥នាក់ ដែលជានាយក នាយិកា និងអ្នកតំណាងពីខាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។

វគ្គនេះមានគោលបំណងផ្តល់ឱកាសដល់អ្នកចូលរួមបានចែករំលែកបទពិសោធន៍ ចំណេះដឹង និងការសិក្សាអំពីប្រព័ន្ធគ្រប់គ្រងទិន្នន័យកុមារ និងយុវជនប្រឈមនឹងហានិភ័យ។

លោក សេង សុធី អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកោះកុង បានមានប្រសាសន៍ថា *"ប្រព័ន្ធគ្រប់គ្រងទិន្នន័យកុមារ និងយុវជនប្រឈមនឹងហានិភ័យគឺជាផ្នែកមួយជួយជំរុញ និងតាមដានកុមារងាយរងគ្រោះឱ្យទទួលបានការអន្តរាគមន៍ទាន់ពេលវេលា និងអាចត្រឡប់ចូលរៀនវិញ ជាពិសេសជួយកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស។ ម៉្យាងវិញទៀត ការជំរុញ និងលើកទឹកចិត្តពីមាតាបិតា និងសហគមន៍ ជាផ្នែកយ៉ាងសំខាន់មិនអាចខ្វះបានក្នុងកម្មវិធីសាលាកុមារមេត្រី"*។



*សាលារៀនគោលដៅចំនួន៤៩ ក្នុងខេត្តកោះកុងចូលរួមក្នុងវគ្គបណ្តុះបណ្តាល។*

លទ្ធផលពីវគ្គបណ្តុះបណ្តាលនៅថ្ងៃនេះ ទាំងអង្គការដៃគូ និងអ្នកពាក់ព័ន្ធដទៃទៀតនឹងយកមកធ្វើជាមេរៀន និងរៀបចំវិធីសាស្ត្រថ្មីសម្រាប់បន្តអនុវត្តន៍នៅក្នុងតំបន់គោលដៅរៀងៗខ្លួន។ កម្មវិធីបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យកុមារ និងយុវជនប្រឈមនឹងហានិភ័យ នឹងត្រូវធ្វើការរៀបចំផែនការប្រជុំផ្សព្វផ្សាយនៅតាមសាលារៀន ព្រមទាំងជ្រើសរើសគ្រូបង្គោល ដើម្បីគាំទ្រសកម្មភាពអន្តរាគមន៍នៅក្នុងសាលារៀនរបស់ពួកគេរៀងៗខ្លួន និងអនុវត្តសកម្មភាពនេះឱ្យបានទាន់ពេលវេលាតាមផែនការគ្រោងទុក៕

អនុវិស័យទី

# ៤

# កម្មវិធីអប់រំបរិយាប័ន្ន

"ភាពចម្រុះ និងការអប់រំបរិយាប័ន្នផ្តល់តម្លៃដល់មនុស្សគ្រប់រូបមិនថាយើងមានភាពខុសគ្នាយ៉ាងណាក៏ដោយ"។

## Inclusive Education

*Diversity and Inclusion are about giving value to every human being, no matter our differences.*



# សិស្សងាយរងគ្រោះទទួលបានកង់សម្រាប់ធ្វើដំណើរទៅសាលារៀន

កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ក្រុមសេនាធិការ (Secretariats) របស់គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា (យីឡា/KYLA) ដោយមានការសម្របសម្រួលពី មន្ត្រីគម្រោង បានរៀបចំកម្មវិធីផ្តល់កង់ជូនដល់សិស្សក្រីក្រចំនួន៧នាក់ (ស្រី៤នាក់) នៅសាលាបឋមសិក្សា បឹងទន្សោង។ សិស្សទាំង៧នាក់នេះត្រូវឆ្លងភូមិសិក្សាឡើងទៅវិទ្យាល័យ ទន្លេបិទ ស្ថិតក្នុងខេត្តត្បូងឃ្មុំ។ បន្ទាប់ពីមានការដាក់សំណើសុំពីលោកនាយកជាច្រើនលើកមកកាន់គម្រោងទាក់ទងនឹងស្ថានភាពសិស្សទាំងនេះ ដែលកំពុងជួបការលំបាកខ្លាំង ព្រោះខ្វះមធ្យោបាយសម្រាប់ធ្វើដំណើរមកសាលារៀនបានទៀងទាត់ពេលវេលា។ គម្រោងយីឡាក៏បានយកកញ្ចប់ថវិកាដែលចូលរួមពីអតីតសិស្សអាហារូបករណ៍អង្គការ ខេប មកទិញកង់ជូនសិស្សទាំង៧នាក់នេះឱ្យមានមធ្យោបាយធ្វើដំណើរទៅសាលារៀនងាយស្រួល និងទាន់ពេលវេលា។

កម្មវិធីចែកកង់នេះមានការចូលរួមពីតំណាងក្រុមប្រឹក្សាឃុំ មេភូមិ គណៈកម្មការអាហារូបករណ៍ នាយកសាលា និងអាណាព្យាបាលសិស្ស។

លោក **សំ អ៊ុល** ជានាយកវិទ្យាល័យព្រែកជីក និងគ្រប់គ្រងសាលាបឋមសិក្សាបឹងទន្សោងដែលជាសាលាឧបសម្ព័ន្ធ បានមានប្រសាសន៍ថា *"ខ្ញុំពិតជារីករាយដែលអង្គការ ខេប បានផ្តល់កង់ជូនដល់សិស្សងាយរងគ្រោះដើម្បីអាចបន្តការសិក្សា។ ខ្ញុំសូមឱ្យប្អូនៗខិតខំប្រឹងប្រែងរៀនសូត្រឱ្យមានអនាគតល្អដើម្បីជួយខ្លួនឯង និងក្រុមគ្រួសារឱ្យមានជីវភាពល្អប្រសើរឡើង"*។

កញ្ញា **ស៊ឹម ផល្លី** ជាតំណាងក្រុមអតីតសិស្សអាហារូបករណ៍ និងជាបុគ្គលិកអង្គការ ខេប បានមានប្រសាសន៍ថា *"ថវិកាដែលទិញកង់ទាំងនេះគឺបានមកពីការចូលរួមរបស់អតីតសិស្សអាហារូបករណ៍ និងសប្បុរសជនផ្សេងៗ ហើយពួកយើងសប្បាយរីករាយក្នុងការផ្តល់ជូន និងជួយដល់សិស្សដែលជួបការខ្វះខាតពិតប្រាកដ"*។

ក្រោយទទួលបានកង់ និងការលើកទឹកចិត្តពីនាយក និងគម្រោងមក សិស្សទាំង៧នាក់បានប្តេជ្ញាចិត្តថានឹងខិតខំប្រឹងប្រែងតស៊ូរៀនសូត្រ និងមកសាលារៀនឱ្យទាន់ពេល៕



*សិស្សងាយរងគ្រោះទាំង៧នាក់ទទួលបានកង់សម្រាប់ឆ្លងភូមិសិក្សាទៅវិទ្យាល័យទន្លេបិទ។*

# គម្រោង GEI រៀបចំកម្មវិធីចែកអាហារូបករណ៍ដល់សិស្សក្រីក្រ

កាលពីថ្ងៃទី៩ ដល់ទី១១ ខែកុម្ភៈ ឆ្នាំ២០២២ គម្រោងអប់រំកុមារី (GEI) ក្រោមជំនួយហិរញ្ញប្បទានពីអង្គការ Lotus Outreach បានរៀបចំកម្មវិធីចែកអាហារូបករណ៍ដល់សិស្សក្រីក្រចំនួន១០០នាក់ នៅសាលារៀនគោលដៅចំនួន៥ រួមមាន៖ អនុវិទ្យាល័យមេមាំង អនុវិទ្យាល័យ ខ្វិតធំ វិទ្យាល័យ ហេង សំរិន ចក អនុវិទ្យាល័យដំរិល និង អនុវិទ្យាល័យ ហ៊ុនសែនទួលសូភី ក្នុងខេត្តត្បូងឃ្មុំ និងកំពង់ចាម។ សមាសភាពចូលរួមសរុបមានចំនួន១៩៦នាក់ដែលជាសិស្សអាហារូបករណ៍ អាណាព្យាបាលសិស្ស តំណាងក្រុមប្រឹក្សាឃុំ ភូមិ នាយកសាលា លោកគ្រូអ្នកគ្រូទទួលបន្ទុកអាហារូបករណ៍ និងបុគ្គលិកគម្រោង។

សិស្សអាហារូបករណ៍ក្នុងមួយនាក់ ទទួលបានសម្លៀកបំពាក់ពីកំប្លេ កាតាបមួយ សៀវភៅ២០ក្បាល កាបូបប៊ិចមួយ ប៊ិចខៀវ៨ដើម ប៊ិកក្រហម២ដើម សម្ភារគណិតមួយកញ្ចប់ ស្បែកជើង១គូ និងដបទឹកមួយ។ ក្នុងនោះ គម្រោងក៏បានផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៧,៥ដុល្លារអាមេរិក (អានបន្តទំព័រ ២២...)



*អាជ្ញាធរដែនដីចូលរួមជាមួយគម្រោងក្នុងការចែកអាហារូបករណ៍ដល់សិស្សក្រីក្រ។*

(...តពីទំព័រ ២១) និងកាតទូរសព្ទចំនួន១៥ ដុល្លាររយៈពេល៣ខែ។

លោក **នួន នីម** ជាតំណាងក្រុមប្រឹក្សាឃុំចក បានមានប្រសាសន៍ថា *"ខ្ញុំពិតជាសប្បាយរីករាយយ៉ាងខ្លាំង ដែលគម្រោងបានជួយជ្រោមជ្រែងដល់សិស្សដែលមានជីវភាពខ្វះខាតនៅក្នុងឃុំរបស់ខ្ញុំ និងសូមឱ្យប្អូនៗសិស្សានុសិស្សបន្តខិតខំប្រឹងប្រែងរៀនសូត្រ ដើម្បីក្លាយជាធនធានល្អសម្រាប់ជួយក្រុមគ្រួសារឱ្យមានជីវភាពល្អប្រសើរតាមរយៈការទទួលបានការអប់រំ"*។

កម្មវិធីចែកអាហារូបករណ៍បានដំណើរការទៅដោយជោគជ័យ និងមានការសហការពីតំណាងការិយាល័យអប់រំ យុវជន និងកីឡាស្រុក ក្រុមប្រឹក្សាឃុំ នាយកសាលា និងអាណាព្យាបាលសិស្ស។ សិស្សអាហារូបករណ៍បានប្ដេជ្ញាខិតខំរៀនសូត្រ និងពុះពាររាល់ការលំបាកដើម្បីទៅសាលារៀន៕



*គម្រោង GEI បានជួយលើកទឹកចិត្ត និងផ្តល់សិទ្ធិអំណាចដល់ក្មេងស្រីជួបការលំបាកប្រឈមនឹងការបោះបង់ការសិក្សា អាចបន្តការសិក្សានៅអនុវិទ្យាល័យ ជាពិសេសគម្រោងបានផ្តល់ការប្រឹក្សាអំពីការជ្រើសរើសគ្រឹះស្ថានសិក្សាល្អៗបន្ទាប់ពីពួកគាត់បញ្ចប់ការសិក្សាពីសាលាចំណេះដឹងទូទៅរួច។*

# កិច្ចប្រជុំក្រុមសេនាធិការរបស់គម្រោង KYLA

កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា (ឃីឡា/KYLA) បានរៀបចំការប្រជុំជាមួយក្រុមសេនាធិការគម្រោងនៅរមណីយដ្ឋានហាន់ជ័យបាមប៊ូ រីសត ដែលមានអ្នកចូលរួមសរុបចំនួន១០នាក់ជាសេនាធិកា ដោយមានការសម្របសម្រួលពីមន្ត្រីគម្រោងឃីឡា។

កិច្ចប្រជុំនេះមានគោលបំណងសំខាន់ផ្តោតទៅលើៈ ១-ការធ្វើបច្ចុប្បន្នភាពទាក់ទងនឹងគម្រោងឃីឡា។ ២-ការរៀបចំផែនការរបស់គម្រោងក្នុងឆ្នាំ២០២២ និង ៣-ការរៀបចំឯកសារមេរៀនក្នុងការបង្រៀនទាក់ទងទៅនឹងការសិក្សាស្រាវជ្រាវបែបចូលរួម និងការចែករំលែកដល់សិស្សស្ម័គ្រចិត្តនៅតាមសាលាគោលដៅនីមួយៗ។



*ក្រុមសេនាធិការប្រជុំគ្នាដើម្បីរៀបចំឯកសារក្នុងការបណ្តុះបណ្តាលដល់សិស្សស្ម័គ្រចិត្ត នៅតាមសាលារៀនគោលដៅរបស់គម្រោង។*

ក្រុមសេនាធិកាបានជជែកពិភាក្សាយ៉ាងលម្អិតលើចំណុចសំខាន់ៗក្នុងការសិក្សាស្រាវជ្រាវ ដូចជា ការកំណត់ប្រធានបទ កម្រងសំណួរ កំណត់អ្នកចុះសម្ភាសន៍ កំណត់អ្នកផ្តល់បទសម្ភាសន៍ វិសាលភាពទីតាំង ផែនការចុះសម្ភាសន៍ និងអនុវត្តសកម្មភាពចុះសម្ភាសន៍ វិភាគលទ្ធផល ការធ្វើរបាយការណ៍ និងបទបង្ហាញលទ្ធផលពីការសិក្សាស្រាវជ្រាវ។

កិច្ចនេះសម្រេចរៀបចំឯកសារបង្រៀនទាក់ទងទៅនឹងការសិក្សាស្រាវជ្រាវបែបចូលរួមសម្រាប់បណ្តុះបណ្តាលសិស្សស្ម័គ្រនៅតាមសាលារៀនគោលដៅរបស់គម្រោងឃីឡា៕

# ហេតុអ្វីត្រូវធ្វើការឆ្លុះបញ្ចាំងអំពីការអនុវត្តកម្មវិធីអាហារូបករណ៍?



*សកម្មភាពលោកគ្រូអ្នកគ្រូក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាល និងវិធានការការពារពីជំងឺកូវីឌ-១៩។*

គម្រោងអប់រំកុមារី (GEI) ក្រោមជំនួយហិរញ្ញប្បទានពីអង្គការ Lotus Outreach បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការឆ្លុះបញ្ចាំងការអនុវត្តកម្មវិធីអាហារូបករណ៍ និងរៀបចំផែនការបង្រៀនបំប៉ន នៅសាលារៀនគោលដៅចំនួន៥ផ្សេងៗក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ កាលពីថ្ងៃ០៣-០៤ ខែមីនា ឆ្នាំ២០២២ ដែលមានអ្នកចូលរួមសរុបមានចំនួន ២២នាក់ ដែលជាតំណាងមកពីការិយាល័យអប់រំ យុវជន និងកីឡាស្រុក នាយក/នាយិកា លោកគ្រូអ្នកគ្រូទទួលបន្ទុកអាហារូបករណ៍ គ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងភាសាអង់គ្លេស ។

វគ្គបណ្តុះបណ្តាលនេះមានគោលបំណងសំខាន់ៗដូចខាងក្រោម៖ **១**-ធ្វើបទបង្ហាញសង្ខេបពីគម្រោងអប់រំកុមារី (GEI)។ **២**-ធ្វើបច្ចុប្បន្នភាពសកម្មភាព លទ្ធផល និងបញ្ហាប្រឈមរបស់គ្រូទទួលបន្ទុកអាហារូបករណ៍។ **៣**-បង្ហាញទម្រង់ឯកសារនានាសម្រាប់គ្រូទទួលបន្ទុកអាហារូបករណ៍ និងគ្រូតាមមុខវិជ្ជានីមួយៗ។ **៤**-រៀបចំកាលវិភាគបំប៉នបន្ថែមលើមុខវិជ្ជានីមួយៗដល់សិស្សអាហារូបករណ៍ និងរៀបចំផែនការបន្ត។

ឆ្នាំនេះជាឆ្នាំទី៣របស់គម្រោងអប់រំកុមារី ហើយវាក៏ជាឆ្នាំចុងក្រោយសម្រាប់ការអនុវត្តសកម្មភាពគម្រោងក្នុងការជួយគាំទ្រដល់សិស្សដែលងាយរងគ្រោះ និងបាត់បង់ឱកាសនៅសាលារៀនគោលដៅចំនួន៥ ដែលមានសិស្សអាហារូបករណ៍សរុបចំនួន១០០នាក់ ។

គម្រោងបានផ្តល់ថ្នាក់បំប៉នបន្ថែមសម្រាប់សិស្សអាហារូបករណ៍លើ៣មុខវិជ្ជា ដូចជា ភាសាខ្មែរ គណិតវិទ្យា និងភាសាអង់គ្លេស ដើម្បីពង្រឹងសមត្ថភាព និងចំណេះដឹងដល់ពួកគាត់ ដែលអាចជួយពួកឱ្យឆ្លងផុតមធ្យមសិក្សាបឋមភូមិបានដោយជោគជ័យ។ ថ្នាក់បំប៉ននេះបានប្រព្រឹត្តទៅរយៈពេល៦ខែ គិតចាប់តាំងពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ រហូតដល់ខែសីហា ឆ្នាំ២០២២។ គម្រោង GEI បានធ្វើឱ្យក្មេងស្រីដែលងាយរងគ្រោះមានជម្រើសជីវិតកាន់តែច្រើននៅក្នុងផែនការអនាគតរបស់ពួកគេ៕

# ការពង្រឹងការជួយបង្រៀនកុមារតាមខ្នងផ្ទះ

កាលពីថ្ងៃទី១១-១៥ ខែមីនា ឆ្នាំ២០២២ គម្រោងងាយស្រួលរៀន (E2L) ក្រោមហិរញ្ញប្បទានពីអង្គការឆាលហ្វាន់ កូរ៉េខាងត្បូង បានរៀបចំកិច្ចប្រជុំជាមួយមាតាបិតា និងអាណាព្យាបាលសិស្សស្តីពី ការជួយបង្រៀនកុមារតាមខ្នងផ្ទះ ដែលធ្វើឡើងនៅតាមសាលារៀនគោលដៅចំនួន៩របស់គម្រោងក្នុងខេត្តក្រចេះ ដោយមានអ្នកចូលរួមសរុបចំនួនប្រមាណជា ១.១០០នាក់ ជាមាតាបិតា និងអាណាព្យាបាលសិស្ស ព្រមទាំងលោកគ្រូអ្នកគ្រូ។

ការប្រជុំនេះត្រូវបានធ្វើឡើងក្នុងគោលបំណងផ្សព្វផ្សាយដល់មាតាបិតា និងអាណាព្យាបាលសិស្សឱ្យចូលរួមខ្ចីសម្ភារសិក្សាទៅបង្រៀនកូនៗនៅតាមផ្ទះបន្ថែម។

គណៈនាយក និងបណ្ណារក្សបានធ្វើបទបង្ហាញពីសារៈសំខាន់នៃការប្រើប្រាស់សម្ភារសិក្សា ល្បែងសិក្សា សៀវភៅរឿង និងកម្មវិធីសិក្សាមួយចំនួនក្នុងទូរសព្ទសម្រាប់មាតាបិតាសិស្សទុកបង្រៀនកូនៗនៅតាមផ្ទះរបស់ពួកគាត់។

ខ្ចីសៀវភៅរឿង និងសៀវភៅសិក្សាផ្សេងៗយកទៅឱ្យកូនរៀន និងជំរុញឱ្យកូនៗចូលអានសៀវភៅនៅក្នុងបណ្ណាល័យ ព្រមទាំងបានចូលរួមចំណែកជួយបង្ហាត់បង្រៀនកូនៗនៅផ្ទះផងដែរ៕



*សកម្មភាពអ្នកគ្រូបង្ហាញអាណាព្យាបាលសិស្សឱ្យចូលរួមខ្ចីសម្ភារសិក្សាក្នុងបណ្ណាល័យ ទៅបង្រៀនសិស្សនៅផ្ទះ។*

# សកម្មភាពការសិក្សាស្រាវជ្រាវបែបចូលរួម



*សកម្មភាពសិស្សសរសេរពីអាជីពមួយចំនួនទាក់ទងទៅនឹងការងារសមរម្យ។*

ក្នុងចន្លោះពេលថ្ងៃទី០៩ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា(ឃីឡា/KYLA) បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី ការស្រាវជ្រាវបែបចូលរួម នៅតាមសាលារៀនគោលដៅចំនួនប្រាំពីរ ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។ សមាសភាពចូលរួមសរុបចំនួន១៧៣នាក់ ជាសិស្សស្ម័គ្រចិត្តរបស់គម្រោង។ វគ្គបណ្ដុះបណ្ដាលនេះមានគោលបំណង៖ ១-ផ្ដល់ឱ្យយុវជនបានយល់ដឹងពីនិយមន័យ និងតួនាទីរបស់ខ្លួន។ ២-សង្ខេបបាននូវនិយមន័យការសិក្សាស្រាវជ្រាវបែបចូលរួម។ ៣-បកស្រាយបានពីអត្ថន័យនៃពាក្យ "**ការងារសមរម្យ**"។ ៤-រៀបរាប់ពីដំណើរការប្រមូលទិន្នន័យ។ ៥-សម្ដែងតួអំពីរបៀបសម្ភាសន៍ និងរៀបចំផែនការសម្រាប់ចុះសម្ភាសន៍។

ការសិក្សាស្រាវជ្រាវបែបចូលរួម គឺជាការស្វែងយល់ពីបញ្ហា និងតម្រូវការនៅក្នុងសហគមន៍ ឬពិភពលោក ដើម្បីចងក្រងរបាយការណ៍ធ្វើបទបង្ហាញ និងផ្សព្វផ្សាយលទ្ធផលទៅកាន់អ្នកពាក់ព័ន្ធក្នុងគោលបំណងតស៊ូមតិឱ្យមានការផ្លាស់ប្ដូរ។ យុវជនដែលចូលរួមវគ្គនេះបានយល់ដឹងអំពីដំណើរការប្រមូលទិន្នន័យ អនុវត្តការសម្ភាសន៍ ការវិភាគទិន្នន័យ និងការធ្វើរបាយការណ៍ក៏ដូចជាការធ្វើបទបង្ហាញអំពីលទ្ធផល។

យុវជនស្ម័គ្រចិត្តចំនួនពី៦០% ទៅ៨០% បានយល់ដឹងអំពីមេរៀននេះច្បាស់ ហើយនឹងយកមេរៀនទាំងនេះទៅអនុវត្តជាក់ស្ដែង៕

# កម្មវិធីចែកសម្ភារសិក្សាជូនដល់សិស្សអាហារូបករណ៍

កាលពីថ្ងៃទី០១ ដល់ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ គម្រោងបង្កើនភាពងាយស្រួលដល់ការអប់រំ និងលទ្ធភាពទទួលបានការងារតាមរយៈការចូលរួមពីសហគមន៍ (BMZ) ក្រោមជំនួយហិរញ្ញប្បទានពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍តាមរយៈអង្គការឆាលហ្វានអាទ្បីម៉ង បានរៀបចំកម្មវិធីចែកសម្ភារសិក្សាជូនដល់សិស្សអាហារូបករណ៍សរុបចំនួន៤១០នាក់ដល់សាលារៀនគោលដៅចំនួន៤១នៅក្នុងខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង និងខេត្តព្រៃវែង។

គោលបំណងកម្មវិធីចែកសម្ភារៈសិក្សានេះ គឺដើម្បីជួយគាំទ្រដល់គ្រួសារសិស្សក្រីក្រនៅកម្រិតបឋមសិក្សា អាចបន្តការសិក្សារបស់ពួកគេនៅកម្រិតអនុវិទ្យាល័យ និងជំរុញឪពុកម្ដាយ និងអាណាព្យាបាលសិស្សឱ្យតាមដានការសិក្សារបស់កូនៗ និងលើកទឹកចិត្តពួកគេក្នុងការរៀនសូត្រ។

សិស្សអាហារូបករណ៍ក្នុងម្នាក់ទទួលបានសៀវភៅសរសេរចំនួន១៥ក្បាល ប៊ិកខៀវ៣ដើម ប៊ិចក្រហម២ដើម កាបូបមួយ ឯកសណ្ឋានសិស្ស២កំប្លេ ស្បែកជើងផ្ទាត់មួយគូ និងកង់សម្រាប់សិស្សដែលមានផ្ទះឆ្ងាយពីសាលារៀន។

តំណាងអាណាព្យាបាលសិស្សម្នាក់សុំមិនបញ្ចេញឈ្មោះបានបង្ហាញមតិចំណាប់អារម្មណ៍ចំពោះគម្រោងថា "*ខ្ញុំសូមអរគុណដល់អង្គការ ខេប និងម្ចាស់ជំនួយដែលបានខិតខំប្រឹងប្រែងស្វែងរកថវិកាដើម្បីមកជួយគាំទ្រដល់គ្រួសារសិស្សក្រីក្រក្នុងតំបន់របស់ពួកយើង និងធ្វើឱ្យកូនៗទាំងអស់គ្នារបស់ពួកយើងទទួលបានការអប់រំប្រកបដោយប្រសិទ្ធភាព ហើយខ្ញុំនឹងលើកទឹកចិត្ត និងជំរុញឱ្យកូនៗខិតខំប្រឹងប្រែងរៀនសូត្រ និងមិនឱ្យពួកគេធ្វើការចំណាកស្រុកទៅប្រទេសក្រៅឡើយ*"។

កម្មវិធីចែកសម្ភារសិក្សាដំណើរការទៅដោយជោគជ័យក្រោមកិច្ចសហការដ៏ល្អពីមន្ទីរ-ការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ស្រុក នាយក នាយិកា គណៈគ្រប់គ្រងសាលារៀន មេភូមិ ក្រុមប្រឹក្សាឃុំ លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធផ្សេងៗបានជួយសម្របសម្រួលដ៏ស្និទស្នាល៕



*សិស្សក្រីក្រដែលមានផ្ទះនៅឆ្ងាយពីសាលារៀននឹងទទួលបានកង់មួយ។*

# ផលផ្លាស់ប្តូរវិជ្ជមានរបស់នាយក និងគណៈកម្មការគ្រប់គ្រងសាលារៀន



ទិដ្ឋភាពសាលាក្រោយគម្រោងអន្តរាគមន៍



ទិដ្ឋភាពសាលាមុនពេលគម្រោងអន្តរាគមន៍

លោក ថាំ ប៊ុនធឿប បានកាន់តួនាទីជានាយកនៅសាលាបឋមសិក្សា តាសែង ចាប់តាំងពីឆ្នាំ២០១៦ រហូតមកដល់បច្ចុប្បនេះ មានរយៈពេល៦ឆ្នាំ និងបានឆ្លងកាត់បញ្ហាប្រឈមយ៉ាងជាច្រើនទម្រាំធ្វើឱ្យសាលារៀនរបស់លោកចាប់ផ្តើមមានការផ្លាស់ប្តូរមុខមាត់ថ្មី សិស្សានុសិស្សសកម្មក្នុងការរៀនសូត្រ និងទទួលបានការគាំទ្រពីសហគមន៍ និងអ្នកពាក់ព័ន្ធនៅក្នុងមូលដ្ឋាន ជាពិសេសការងារសហការយ៉ាងសកម្មជាមួយគណៈកម្មាការគ្រប់គ្រងសាលារៀន ធ្វើឱ្យសាលារៀនមានវឌ្ឍនភាពយ៉ាងឧត្តុងឧត្តម។

សាលាបឋមសិក្សា តាសែង ស្ថិតក្នុងភូមិតាសែង ឃុំស្ទួល ស្រុកឡាញ់ ខេត្តសៀមរាប មានចម្ងាយ២៥គីឡូម៉ែត្រពីការិយាល័យអប់រំ យុវជន និងកីឡាស្រុក មានសិស្សសរុបចំនួន ២៦៤នាក់ មកពីគ្រួសារចំនួន៣៣១ ប្រកបមុខរបរធ្វើស្រែ និងចំណាកស្រុកទៅរកការងារធ្វើនៅស្រុកក្រៅប្រទេស។

នៅមុនពេលមានអន្តរាគមន៍ពីគម្រោងកុមារកម្ពុជារីករាយ (HCC) សាលានេះមានបញ្ហាប្រឈមជាច្រើនៗ ដូចជា វិធីសាស្ត្របង្រៀនរបស់លោកគ្រូអ្នកគ្រូអនុវត្តតាមទម្លាប់ចាស់ ដោយប្រើប្រាស់តែសៀវភៅសិក្សាគោល បរិស្ថានសាលារៀនគ្មានវិធីថ្មីរៀបចំឱ្យស្រស់ស្អាត ខ្វះខាតទឹកប្រើប្រាស់ គ្មានបណ្ណាល័យ សិស្សរៀនខ្សោយ ហើយមានការបោះបង់ការសិក្សាច្រើន ខ្វះសម្ភារៈក្នុងការបង្រៀន និងរៀន ជាពិសេសឪពុកម្តាយ និងអាណាព្យាបាលសិស្សភាគច្រើនយល់ដឹងអំពីការអប់រំនៅមានកម្រិត។ ការផ្សព្វផ្សាយព័ត៌មាន និងការទំនាក់ទំនងរវាងសាលារៀនជាមួយឪពុកម្តាយមិនទាន់សកម្ម និងល្អនៅឡើយ។ ចំណែកនាយក គណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកពាក់ព័ន្ធបានព្យាយាមដាក់សំណើរសុំទៅកាន់អង្គការដៃគូ និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក តែទទួលបានការឆ្លើយតបយឺតយ៉ាវ។

លោកថាំ ប៊ុនធឿប និងគណៈកម្មការទ្រទ្រង់សាលារៀននៅតែបានបន្តខិតខំប្រឹងប្រែងរកអង្គការដៃគូ និងសប្បុរសជនដទៃទៀតមកជួយអភិវឌ្ឍសាលារៀន និងបង្កើនបានបន្ទប់សិក្សាគ្រប់គ្រាន់ដល់សិស្ស។ បច្ចុប្បន្ននេះសាលាបឋមសិក្សា តាសែង មានបន្ទប់សិក្សាចំនួន១០។ នៅក្នុងឆ្នាំ២០១៨ សាលាបឋមសិក្សា តាសែង ទទួលបានការអន្តរាគមន៍ពីគម្រោង HCC បានធ្វើឱ្យសាលានេះផ្លាស់ប្តូររីកចម្រើនជឿនលឿន ដែលក្នុងនោះរួមមាន៖ ការរៀបចំបរិស្ថានក្នុងថ្នាក់ និងក្រៅថ្នាក់តាមបច្ចេកទេសថ្មី ការជួសជុលអគារសិក្សាចាស់ទៅជាថ្មីប្រកបដោយសោភ័ណភាព បង្កើតបណ្ណាល័យស្តង់ដាដែលបំពាក់ដោយសម្ភារៈទំនើបមានសៀវភៅសិក្សាច្រើន ការរៀបចំថ្នាក់រៀនដោយភាពច្នៃប្រឌិត ការរៀបចំបន្ទប់ទឹក កន្លែងកុមារញ៉ាំអាហារ កន្លែងដាក់កង់ម៉ូតូ សួនជីវៈចម្រុះ ការរៀបចំសួនដាំផ្កាលម្អមុខថ្នាក់រៀន។ល។ គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់នាយក គណៈកម្មាការទ្រទ្រង់សាលា និងលោកគ្រូអ្នកគ្រូ របៀបរៀបចំប្រជុំប្រចាំខែ ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាការ ការផ្សព្វផ្សាយព័ត៌មានពីសាលារៀនដល់ឪពុកម្តាយ និងទទួលព័ត៌មានពីឪពុកម្តាយ។ លោក ប៊ុនធឿប មានសេចក្តីរំភើបសប្បាយរីករាយដោយសារសាលារៀនរបស់លោកមានការរីកចម្រើនលើន ជាពិសេសការផ្លាស់ប្តូរឥរិយាបទរបស់លោក និងគណៈកម្មាការទ្រទ្រង់សាលារៀន ស្គាល់ពីតួនាទីនិងភារកិច្ចច្បាស់ជាងមុន និងមានការទំនាក់ទំនងល្អជាមួយឪពុកម្តាយអាជ្ញាធរឃុំ សហគមន៍ និងអ្នកពាក់ព័ន្ធ។

លោក ថាំ ប៊ុនធឿប និងគណៈកម្មាការទ្រទ្រង់សាលារៀនពិតជាបានទទួលនូវការជួយជ្រោងជ្រែងច្រើនពីគម្រោង ដែលជាមូលហេតុធ្វើឱ្យការដឹកនាំរបស់លោកមានវឌ្ឍនភាព ទាក់ទាញបាន (អានបន្តទំព័រ ២៦...)


សោភ័ណភាពក្នុងសាលារៀនបន្ទាប់ពីមានការអន្តរាគមន៍គម្រោង HCC។

(...តពីទំព័រ២៥) ការចូលរួមពីសហគមន៍ អ្នកពាក់ព័ន្ធ ជាពិសេសការសិក្សារបស់សិស្សមានការកើនឡើងជាងមុន។ ទោះបីស្ថិតក្នុងកាលៈទេសៈលំបាកពីការរាតត្បាតជំងឺកូវី-១៩ក៏ដោយ ក៏លោក និងគណៈកម្មការគ្រប់គ្រងសាលារៀនមានកំលាំងចិត្តចូលរួមតស៊ូជាមួយគម្រោង HCC ដើម្បីធ្វើយ៉ាងឱ្យកុមារកម្ពុជាទទួលបានការអប់រំមានគុណភាព។

លោក ថាំ ប៊ុនធឿប បានមានប្រសាសន៍ថា "*សាលារៀនខ្ញុំមានការរីកចម្រើនដោយសារមានការបណ្តុះបណ្តាលទាំងជំនាញទន់ និងបច្ចេកទេសពីគម្រោងដល់គ្រូ ការចូលរួមនិងគាំទ្រពីសហគមន៍ អត្រាសិស្សបោះបង់ការសិក្សាបានធ្លាក់ចុះ។ ចំនួនសិស្សចុះឈ្មោះចូលរៀន*


*លោក ថាំ ប៊ុនធឿប នាយកបឋមសិក្សា តាសែង*

*កើនឡើងមកពីសាលារៀនមានបរិស្ថានក្នុងថ្នាក់និងក្រៅថ្នាក់ស្អាត និងគ្រូមានបច្ចេកទេសបង្រៀនល្អ។ ខ្ញុំបានយល់ពីការរៀបចំផែនការអភិវឌ្ឍសាលារៀនប្រចាំឆ្នាំកាន់តែច្បាស់ របៀបគ្រប់គ្រង និងដឹកនាំ ដំណើរការរៀបចំកែលម្អបរិស្ថាន យល់ដឹងពីការចងក្រងជាឯកសារ ជំរុញឱ្យលោកគ្រូអ្នកគ្រូសកម្មក្នុងការបង្រៀន ចេះដឹងពីវិធីសាស្ត្រសម្របសម្រួល ផ្តល់ព័ត៌មានត្រឡប់ និងចេះប្រើប្រាស់បច្ចេកវិទ្យាមួយចំនួន*"។

លោក **ភី គង់** ជាសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀនបានមានប្រសាសន៍ថា "*សហគមន៍បានសរសើរអំពីបរិស្ថានក្នុងសាលារៀនមានភាពស្រស់ស្អាត ជាពិសេសកុមារសប្បាយចិត្តក្នុងការរៀនសូត្រ។ ខ្ញុំពិតជាសប្បាយចិត្តចំពោះការគាំទ្ររបស់គម្រោងដល់សាលារៀនបឋមសិក្សា តាសែង ដែលស្ថិតនៅ*


*លោក ភី គង់ សមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន។*

*ក្នុងតំបន់ដាច់ស្រយាលឱ្យមានទិដ្ឋភាពស្រស់បំព្រងស្អាត ជាពិសេសបានផ្តល់ជាស្បៀងអាហារដល់កុមារដែលមានជីវភាពខ្វះខាតក្នុងអំឡុងពេលការរាតត្បាតពីជំងឺកូវីដ-១៩។ ម្យ៉ាងវិញទៀត ខ្ញុំបានផ្លាស់ប្តូរឥរិយាបទដោយសារខ្ញុំបានស្គាល់ច្បាស់អំពីតួនាទីភារកិច្ច និងការធ្វើផែនការសាលារៀនច្បាស់ជាងមុន*"។

លោកនាយក និងគណៈកម្មការគ្រប់គ្រងសាលារៀនបានដឹកនាំសាលារៀនរីកចម្រើនទាំងហេដ្ឋារចនាសម្ព័ន្ធសាលារៀន ការទំនាក់ទំនងជាមួយសហគមន៍ ឪពុកម្តាយ និងអាណាព្យាបាលសិស្សនៅមូលដ្ឋានមានការយល់ដឹងអំពីការអប់រំ ហើយបានបញ្ជូនកូនមកសាលារៀនកាន់តែច្រើនឡើង។ កុមារនៅក្នុងគ្រួសារជីវភាពលំបាក និងងាយរងគ្រោះបានទទួលសេវាអប់រំប្រកបដោយគុណភាព។ ទំនាក់ទំនងរវាងសាលារៀន និងឪពុកម្តាយសិស្សបានប្រែក្លាយទៅជាមានសកម្មភាពយ៉ាងរស់រវើក ជាពិសេសការផ្តល់ព័ត៌មានអំពីការសិក្សាកូនដល់ឪពុកម្តាយ និងអាណាព្យាបាល និងការបញ្ជូនព័ត៌មានត្រឡប់មកកាន់សាលារៀនវិញ ដែលនេះមានន័យថាសុខទុក្ខសិស្សានុសិស្ស ឪពុកម្តាយ និងអាណាព្យាបាល និងសាលារៀនគឺនៅជាមួយគ្នា។


*កន្លែងកុមារលាងដៃ និងបង្គន់អនាម័យបានបង្កើតឡើងមានបរិយាកាសស្រស់ល្អ។*


*សកម្មភាពគ្រូចូលរួមកែច្នៃសួនច្បារមុខថ្នាក់រៀនយ៉ាងសកម្ម និងមមាញឹកច្រើន។*

អនុវិស័យទី ៥

# កម្មវិធីអំណានថ្នាក់ដំបូង

“នៅពេលអ្នករៀនអាន អ្នកនឹងមានសេរីភាពរហូត”។

# Early Grade Reading

*Once you learn to read, you will be forever free.*



# ការពង្រឹងសមត្ថភាពសិស្សលើផ្នែកអំណានថ្នាក់ដំបូង

ការពង្រឹងអំណានថ្នាក់ដំបូង គឺជាផ្នែកដ៏សំខាន់មួយក្នុងចំណោមផ្នែកទាំង១០ ដែលគម្រោងអង្គការ ខេប កំពុងប្រតិបត្តិនៅតាមសាលារៀនគោលដៅក្នុង១៣ រាជធានី-ខេត្តក្នុងប្រទេសកម្ពុជា។ តាមរបាយការណ៍ប្រចាំ២០២១របស់អង្គការ ខេប មានគម្រោងចំនួន៩បានយកចិត្តទុកលើការពង្រឹងអំណានដល់កុមារ។ ការគាំទ្រ និងអន្តរាគមន៍របស់គម្រោងដល់សាលារៀនគោលដៅរួមមាន៖



*សកម្មភាពសិស្សចូលអានសៀវភៅក្នុងបណ្ណាល័យពេលម៉ោងចេញលេង។*

**ទី១** គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលជាច្រើនដល់លោកគ្រូអ្នកគ្រូទាក់ទងទៅនឹងការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែម វិធីសាស្ត្របង្រៀន និងរៀន របៀបធ្វើកិច្ចតែងការបង្រៀន ការតុបតែងថ្នាក់រៀន និងមានសកម្មភាពជាច្រើនទៀតដែលគាំទ្រ និងពង្រឹងសមត្ថភាពគ្រូបង្រៀនក្នុងការផ្ទេរចំណេះដឹងទៅកាន់សិស្សប្រកបដោយគុណភាព។ ទោះបីជាទទួលរងនូវផលប៉ះពាល់ពីជំងឺកូវីដ១៩យ៉ាងណាក៏ដោយ គម្រោងអង្គការ ខេប ទាំងអស់នៅតែគាំទ្រជំរុញ និងលើកទឹកចិត្តឱ្យលោកគ្រូអ្នកគ្រូនៅតាមសាលារៀនគោលដៅ ចុះអន្តាគមន៍បង្រៀនតាមបណ្តុំតាមផ្ទះ ផ្តល់សម្ភារៈសិក្សាឱ្យសិស្សខ្ចី និងបានស្វះស្វែងរកវិធីសាស្ត្រធ្វើយ៉ាងណាដើម្បីឱ្យការបង្រៀនសិស្សទាន់កម្មវិធីសិក្សារដ្ឋ ជាពិសេសជួយអន្តរាគមន៍បន្ថែមទៅលើសិស្សរៀនយឺត។

**ទី២** គម្រោងបានផ្តល់សៀវភៅរឿងនិទាន និងសម្ភារៈសិក្សាជាច្រើនប្រភេទដល់បណ្ណាល័យសម្រាប់សិស្សមានជម្រើសជ្រើសរើសសៀវភៅ ដែលពួកគេពេញចិត្តក្នុងការអាន លេងល្បែងសិក្សា ខ្ចីសៀវភៅ និងសិក្សាស្រាវជ្រាវ។ ដូចគ្នានេះដែរ គម្រោងក៏បានផ្តល់ Tablets ដល់សាលារៀនគោលដៅរបស់ខ្លួនទាំងអស់ដាក់ក្នុងបណ្ណាល័យដើម្បីទាក់ទាញសិស្សានុសិស្សឱ្យចូលបណ្ណាល័យ ដោយមាន Tablets សម្រាប់សិក្សារៀនសូត្រ និងមានកម្មវិធីសិក្សាជាច្រើនសម្រាប់ពង្រឹងអំណានថ្នាក់ដំបូង ដូចជា **កម្មវិធីអានខ្មែរ កម្មវិធីសរសេរខ្មែរ** និង**កម្មវិធីសៀវភៅឆ្លាត**។

**ទី៣** គម្រោងតែងតែធ្វើការវាយតម្លៃអំណានថ្នាក់ដំបូងចុងឆ្នាំ និងដើមឆ្នាំដើម្បីធ្វើការតាមដានផ្នែកអំណានរបស់សិស្សក្នុងសាលារៀនគោលដៅដែលគម្រោងបានគាំទ្រផ្នែកបច្ចេកទេសបង្រៀនកន្លងមក។



*សកម្មភាពកុមារប្រើប្រាស់កម្មវិធីសិក្សាលើនៅលើ Tablets ក្នុងការពង្រឹងលើផ្នែកអំណាន។*

គម្រោងបានយកចិត្តទុកដាក់ និងផ្តោតសំខាន់លើផ្នែកអំណានថ្នាក់ដំបូង តាមរយៈការអន្តរាគមន៍ផ្សេងៗ ផ្តល់វិធីសាស្ត្របង្រៀនល្អៗក្នុងការគ្រប់គ្រងសិស្ស ផ្តល់ចំណេះដឹងដល់សិស្ស ក៏ដូចជាលើកកម្ពស់ការសិក្សាក្នុងថ្នាក់រៀន មានសម្ភារៈសិក្សាយ៉ាងសម្បូរបែបជំរុញឱ្យសេវាកម្មបណ្ណាល័យដំណើរការបានទៀងទាត់ និងមានការជួយបន្ថែមពីសិស្សធំជួយបង្រៀនសិស្សតូច។ ដូច្នេះ កុមារអាចបង្កើនសមត្ថភាពអានដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់រៀនមុខវិជ្ជាដ៏ទៃទៀត៕

អនុវិស័យទី ៦

# កម្មវិធីមត្តេយ្យសិក្សា

"បង្កើនគំនិតមួយសម្រាប់កុមារមួយនាក់ក្នុងពេលតែមួយ"។

# Preschool Programming

*Enriching the mind one child at a time.*













# ការវាស់ស្ទង់ការអភិវឌ្ឍ និងការហាត់រៀនតាំងពីដំបូងរបស់កុមារតូច

កាលពីថ្ងៃទី០១ ដល់ទី០៤ ខែមីនា ឆ្នាំ ២០២២ គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់៣/TRAC III) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី **ការវាស់ស្ទង់ការអភិវឌ្ឍ និងការហាត់រៀនតាំងពីដំបូងរបស់កុមារតូចជាលក្ខណៈសកល (IDELA)** នៅសាលប្រជុំសាលារៀនជំនាន់ថ្មីវិទ្យាល័យ ហ៊ុន សែន កំពង់ចាម ដោយមានអ្នកចូលរួមសរុបចំនួន១៨នាក់ មកពីសាលារៀនគោលដៅទាំង ១២នៅក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។

វគ្គបណ្តុះបណ្តាលនេះធ្វើឡើងដើម្បី៖ **១**-ស្វែងយល់ពីនិតិវិធីវាស់ស្ទង់ការអភិវឌ្ឍ និងការហាត់រៀនតាំងពីដំបូងរបស់កុមារតូចជាលក្ខណៈសកល។ **២**-ពង្រឹងសមត្ថភាពគ្រូចូលរួមក្នុងការប្រើប្រាស់ឧបករណ៍ KoboToolbox ដើម្បីធ្វើឱ្យការវាយតម្លៃទទួលបានគុណភាព និងមានប្រសិទ្ធភាព។ **៣**-រៀបចំគម្រោងចុះធ្វើតេស្ត IDELA ក្នុងសាលារៀនគោលដៅរបស់គម្រោង។


សកម្មភាពអ្នកគ្រូកំពុងអនុវត្តការចុះធ្វើតេស្ត IDELA មុនចុះទៅតាមសាលារៀនគោលដៅ។

អំឡុងពេលបណ្តុះបណ្តាល គ្រូចូលរួមនៅក្នុងវគ្គនេះបានអនុវត្តសាកល្បងច្រើនដងជាក្រុម និងជាដៃគូ ដើម្បីត្រៀមចុះដំណើរការប្រមូលទិន្នន័យឱ្យបានលទ្ធផលល្អប្រសើរ។ ការប្រើឧបករណ៍ IDELA ដើម្បីវាយតម្លៃកម្រិតរៀនសូត្រតាំងពីដំបូងរបស់កុមារ និងសមត្ថភាព អារម្មណ៍ទៅនឹងកត្តាសង្គមតាំងពីកុមារនៅអាយុពី ៣,៥ឆ្នាំទៅ ៦ឆ្នាំ ហើយលទ្ធផលសិក្សារបស់ IDELA នឹងត្រូវបានប្រើប្រាស់ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាដែលសមស្របតាមអាយុ និងតាមបរិបទសម្រាប់កុមារ។

គ្រូចូលរួមវគ្គនេះបានរៀនសូត្រ និងយល់ដឹងអំពីវិធីសាស្ត្រចុះវាយតម្លៃការវាស់ស្ទង់ការអភិវឌ្ឍ និងការហាត់រៀនតាំងពីដំបូងរបស់កុមារតូចក្នុងគោលដៅ៕

# ការងារបច្ចេកទេស និងការប្រើប្រាស់សៀវភៅសិក្សាគោល

កាលពីថ្ងៃទី២៨-២៩ ខែមីនា ឆ្នាំ២០២២ គម្រោងពង្រឹងការអប់រំ និងលទ្ធភាពទទួលបានការងារតាមរយៈការចូលរួមរបស់សហគមន៍ (BMZ) បានរៀបចំវគ្គបណ្តុះបណ្តាលដល់គ្រូមត្តេយ្យកិច្ចសន្យាស្តីពី ការងារបច្ចេកទេស ការប្រើប្រាស់សៀវភៅសិក្សាគោលមុខវិជ្ជាចិត្តចលភាព និងការផលិតសម្ភារៈ ក្រោមការសម្របសម្រួលដោយលោកស្រី ទី គុន្ធា ជាមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា កុមារតូចនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង នៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង។ សមាសភាពចូលរួមសរុបចំនួន១៣នាក់ មកពីសាលារៀនគោលដៅក្នុងខេត្តស្វាយរៀង និងព្រៃវែង។



សកម្មភាពអ្នកគ្រូៗចូលរួមវគ្គបណ្តុះបណ្តាលលើការប្រើប្រាស់សៀវភៅសិក្សាគោល។

វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងក្នុងគោលបំណង៖ **១**-ពង្រឹងសមត្ថភាពគ្រូមត្តេយ្យសិក្សាកិច្ចសន្យាអំពីវិធីសាស្ត្របង្រៀន និងរៀន។ **២**-ធ្វើការឆ្លុះបញ្ចាំងលើការអនុវត្តកន្លងមកទាក់ទងនឹងការបង្រៀន និងរៀន ការគ្រប់គ្រងថ្នាក់រៀន បញ្ហាប្រឈម និងដំណោះស្រាយ។ **៣**-បង្ហាញពីការអនុវត្តសៀវភៅសិក្សាគោលលើមុខវិជ្ជាចិត្តចលភាព និងការរៀបចំជ្រុងទាំង៥ រួមមាន៖ ជ្រុងវិទ្យាសាស្ត្រ ជ្រុងអនាម័យ ជ្រុងសិល្បៈ ជ្រុងល្បែង និងជ្រុងសិក្សា។ **៤**-បង្ហាញពីរបៀបសរសេរកិច្ចតែងការបង្រៀន និងផលិតសម្ភារឧបទេស។

គ្រូចូលរួមទទួលបានចំណេះដឹងល្អៗជាច្រើនទាក់ទងទៅនឹងបច្ចេកទេសក្នុងការបង្រៀន និងរៀន យល់ដឹងពីការប្រើប្រាស់សៀវភៅសិក្សាគោល របៀបរៀបចំថ្នាក់រៀនប្រកបដោយសោភ័ណភាព មានលក្ខណៈទាក់ទាញសិស្សច្រើនជាងមុន និងចេះផលិតសម្ភារឧបទេសសម្រាប់បម្រើដល់ការបង្រៀន និងរៀនល្អប្រសើរ៕

អនុវិស័យទី ៧

# រចនាបថហេដ្ឋារចនាសម្ព័ន្ធ

“ធ្វើឱ្យទម្រង់ការអប់រំស្របតាមតម្រូវការ និងដើរតួនាទីថ្មីៗ”។

# Infrastructure Design

*Making educational forms that follow new needs and functions.*



# តើការបង្កើតបន្ទប់មត្តេយ្យសិក្សាបែបទំនើបមានលក្ខណៈពិសេសអ្វី ?

គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់៣/TRAC III) គឺជាគម្រោងមួយបានលើកកម្ពស់គុណភាពអំណាននៅថ្នាក់ដំបូងដល់កុមារតាមរយៈវិធីសាស្ត្រមួយ ដែលសំដៅលើបរិស្ថានរៀនសូត្ររបស់កុមារ និងមានការវាយតម្លៃទៀងទាត់ ជាពិសេសមានការចូលរួមបង្ហាត់បង្រៀនពីឪពុកម្តាយនៅផ្ទះ។

ការបង្កើតបន្ទប់មត្តេយ្យសិក្សាបែបទំនើបសម្រាប់សាលារៀនគោលដៅទាំងអស់ វាជាសូចនាករដ៏សំខាន់មួយរបស់គម្រោងក្នុងការអនុវត្តគម្រោង។ បច្ចុប្បន្ននេះ គម្រោងបានកែលម្អបន្ទប់មត្តេយ្យសិក្សាបែបទំនើបបានចំនួន៦សាលា ក្នុងចំណោម១៨សាលា ដែលបានជួសជុលបន្ទប់សិក្សាចាស់ទៅជាបន្ទប់សិក្សាថ្មី បានបំពាក់គ្រឿងសង្ហារឹមល្អៗក្នុងថ្នាក់ មានសម្ភារៈល្បែងសិក្សាប្រើប្រាស់យ៉ាងសម្បូរបែបក្នុងថ្នាក់រៀន មានទូរទស្សន៍ និងថែបភ្លែត១គ្រឿងសម្រាប់អ្នកគ្រូងាយស្រួលក្នុងការបង្រៀន និងរៀនប្រកបដោយភាពច្នៃប្រឌិត ព្រមទាំងមានបរិស្ថានសិក្សាប្រកបដោយផាសុកភាព។

ថ្នាក់រៀនមានលក្ខណៈភ្លឺស្រឡះ ការតុបតែងស្អាតបង្កប់ដោយខ្លឹមសារមេរៀន និងមានសោភ័ណភាពទាក់ទាញកុមារចូលចិត្ត និងសប្បាយចិត្តមករៀនសូត្រ។ ចំណុចដែលសំខាន់មួយទៀតគឺកុមារអាចធ្វើសកម្មភាពជាក្រុមរួមគ្នា ពិភាក្សា និងលេងល្បែងសិក្សាបានដោយសេរី និងរីករាយ។ តុអាន និងអង្គុយអាចបំលាស់ទីបានងាយ ហើយកុមារអាចគេងរឺអង្គុយរៀនបានស្រួលដែលនេះគឺជាការអភិវឌ្ឍថ្នាក់រៀនឆ្លើយតបទៅនឹងបរិបទអប់រំក្នុងសតវត្សរ៍ទី២១នេះ៕



*សកម្មភាពកុមារកំពុងលេងល្បែងសិក្សាក្នុងថ្នាក់រៀនពេលចេញលេង។*



*សកម្មភាពកុមារកំពុងមើលការបង្រៀននៅលើកញ្ចក់ទូរទស្សន៍ដែលអាចអង្គុយបានច្រើនសណ្ឋាននៅក្នុងរៀន។*

អនុវិស័យទី

# ៨

# ការអភិវឌ្ឍបណ្ណាល័យ

“បណ្ណាល័យសាលារៀនៈ ជាសោរសម្រាប់អតីតកាល និងជាទ្វារសម្រាប់អនាគត”។

# Library Development

*The School Library Key to the Past and Gateway to the Future.*



# ការអភិវឌ្ឍពីបណ្ណាល័យធម្មតា/បែបប្រពៃណីទៅជាបណ្ណាល័យស្តង់ដា



*សិស្សថ្នាក់ទី៩ C១ ចូលសិក្សាស្រាវជ្រាវអំពី អ៊ីដ្រូសែន ក្នុងម៉ោងសិក្សា គីមីវិទ្យា នៅបណ្ណាល័យសតវត្សរ៍ទី២១ នៃសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប។*

បណ្ណាល័យជាប្រភពនៃចំណេះដឹងគ្រប់បែបយ៉ាងដែលគាំទ្រដល់ការរស់នៅ និងការអភិវឌ្ឍសម្រាប់អ្នកសិក្សាស្រាវជ្រាវ អ្នកនិពន្ធ សិស្ស-និស្សិត និងប្រជាជនទូទៅ។ ការអភិវឌ្ឍបណ្ណាល័យធម្មតា ឬបែបប្រពៃណីឱ្យក្លាយទៅជាបណ្ណាល័យស្តង់ដា ឬជាបណ្ណាល័យសតវត្សរ៍ទី២១ គឺជាអនុវិស័យមួយដ៏សំខាន់នៅក្នុងចំណោមផ្នែកសំខាន់ៗទាំង១០របស់អង្គការ ខេប ដែលត្រូវបានគម្រោងយកចិត្តទុកដាក់ក្នុងការកែលម្អបន្ទប់សិក្សាចាស់ទៅជាបណ្ណាល័យថ្មីមួយប្រកបដោយភាពទាក់ទាញ និងមានផាសុកភាព។ តាមរយៈរបាយការណ៍ប្រចាំឆ្នាំ២០២១របស់អង្គការ ខេប ក្នុងចំណោម២០គម្រោង ក្នុងនោះមានគម្រោងចំនួនដែលបានផ្តោតសំខាន់លើការអភិវឌ្ឍបណ្ណាល័យតាំងពីកម្រិតបឋមសិក្សារហូតដល់វិទ្យាល័យ។

បណ្ណាល័យចាស់ឬមានសភាពទ្រុឌទ្រោមនៅតាមសាលារៀនគោលដៅ ត្រូវបានគម្រោងកែលម្អទៅជាបណ្ណាល័យថ្មីដែលមានភាពច្នៃប្រឌិតនិងមានបរិយាកាសប្រកបដោយសោភ័ណភាព។ ក្នុងករណីសាលារៀនមិនមានបណ្ណាល័យ គម្រោងបានផ្តល់កញ្ចប់ថវិកាមួយចំនួនជូនដល់គណៈគ្រប់គ្រងសាលារៀនដើម្បីធ្វើការគៀងគរថវិកាបន្ថែមក្នុងការសាងសង់បណ្ណាល័យថ្មី។

បណ្ណាល័យស្តង់ដាមានការរៀបចំ និងទុកដាក់សៀវភៅមានរបៀប និងមានការបែងចែកលេខកូដប្រភេទសៀវភៅច្បាស់លាស់ សម្ភារឯកសារក្នុងការសិក្សា ព្រមទាំងមានឧបករណ៍ស្រាវជ្រាវគ្រប់គ្រាន់ ដូចជា Tablets និងកុំព្យូទ័រមានភ្ជាប់អ៊ីនធើណែតសម្រាប់សិស្សានុសិស្សធ្វើការសិក្សាស្រាវជ្រាវ។

អ្នកគ្រូ **អ៊ា សុចិន្តា** ជាបណ្ណារក្សសាលាបឋមសិក្សាបឹងត្រាវបានមានប្រសាសន៍ថា *"ការគាំទ្រពីគម្រោងបានធ្វើឱ្យបណ្ណាល័យមានភាពខុសប្លែកច្រើន ដូចជា ពីមុនមិនសូវសម្ភារសៀវភៅរឿង ល្បែងសិក្សា ហើយសិស្សក៏មិនបានចាប់អារម្មណ៍បណ្ណាល័យ ដោយសារតែបរិស្ថានជុំវិញគ្មានភាពទាក់ទាញ ប៉ុន្តែបច្ចុប្បន្ននេះ អំឡុងម៉ោងចេញលេងម្តងៗ សិស្សានុសិស្សនាំគ្នាមកបណ្ណាល័យអានសៀវភៅរឿង លេងល្បែងសិក្សា និងលេងប្រើប្រាស់ Tablets មានចំនួនច្រើន។ បណ្ណាល័យថ្មីនេះពិតជាបានចូលរួមចំណែកច្រើនដើម្បីបង្កើនសមត្ថភាពអាន និងសិក្សាស្រាវជ្រាវផ្សេងៗ"*។



*សកម្មភាពសិស្សចូលអាន និងលេងល្បែងសិក្សាក្នុងបណ្ណាល័យនៅសាលាបឋមសិក្សាប៊ើស២។*

អនុវិស័យទី ៦

# កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព

“បំណិនជីវិតទទួលបានអត្ថប្រយោជន៍ពីការអប់រំសកម្មភាពគ្រូបង្រៀន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកម្មវិធីសិក្សាឌីណាមិក”។

# Life Skills Education & Career Counseling

*Life Skills benefit from proactive education, Qualified Instructors, Dynamic Curriculum.*



# កម្មវិធីបំណិនជីវិត


សកម្មភាពគ្រូចូលរួមសិក្ខាសាលា សរសេរពីកត្តាជីវសាស្ត្រពីភាពខុសគ្នារវាងបុរស និងស្ត្រី។

គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (ស៊ីក/SEEK) បានរៀបចំសិក្ខាសាលាស្ដីពី "**កម្មវិធីបំណិនជីវិត**" ក្រោមជំនួយហិរញ្ញប្បទានពីសហភាពអឺរ៉ុប នៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ចាម កាលពីថ្ងៃទី០៨-០៩ ខែកុម្ភៈ ឆ្នាំ២០២២។

សិក្ខាសាលានេះមានគោលបំណងឱ្យសិក្ខាកាមចេះប្រើប្រាស់សម្ភារៈពាក់ព័ន្ធ បង្កើតសម្ភារៈ និងគំនិតបង្រៀនផ្ទាល់ខ្លួន ព្រមទាំងអាចផ្សព្វផ្សាយ និងចែករំលែកជាមួយសាលារៀនដទៃៗទៀតដែលកំពុងអនុវត្តកម្មវិធីបំណិនជីវិតនៅនឹងមូលដ្ឋានផ្ទាល់។

សិក្ខាកាមបានស្វែងយល់ពីសារតា និងការប្រើប្រាស់សៀវភៅបំណិនជីវិត ដែលបានរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ពីរបៀបបង្រៀនសាកល្បងមេរៀនបំណិនជីវិត ស្វែងយល់ពីឧបសម្ព័ន្ធនៃសៀវភៅបំណិនជីវិត និងធ្វើផែនការក៏ដូចជាជ្រើសរើសសៀវភៅបំណិនជីវិតសម្រាប់ឆ្នាំថ្មី។

កម្មវិធីបំណិនជីវិតគឺជាសកម្មភាពស្នូលសម្រាប់បង្កើនគុណភាព និងប្រសិទ្ធភាពក្នុងវិស័យអប់រំដែលនឹងផ្ដល់ឱ្យសិស្សនូវចំណេះដឹងមូលដ្ឋានយ៉ាងជ្រៅជ្រះ និងពង្រឹងជំនាញផ្សេងៗដែលមានសារៈសំខាន់សម្រាប់ការស្រូបយកបទពិសោធន៍ល្អៗក្នុងការពង្រឹងចំណេះដឹង និងបំណិនចាំបាច់សម្រាប់បម្រើជីវភាពរស់នៅប្រចាំថ្ងៃ។ គម្រោងស៊ីកបង្កើតឡើងក្នុងគោលបំណងដើម្បីបំពេញនូវសិទ្ធិសេដ្ឋកិច្ច និងសង្គមរបស់យុវជន ជាពិសេសស្ត្រីមកពីសហគមន៍ជនជាតិចាម តាមរយៈការទទួលបានការអប់រំប្រកបដោយគុណភាព និងបរិយាប័ន្ន បណ្ដុះបណ្ដាលវិជ្ជាជីវៈ។

# ឯកសារកម្មវិធីបំណិនជីវិតសម្រាប់បឋមសិក្សា និងមធ្យមសិក្សា

កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងការគាំទ្រសំឡេង ដើម្បីសមធម៌សង្គម (CO-SAVED) បានរៀបចំវគ្គបណ្ដុះបណ្ដាលតាមប្រព័ន្ធអនឡាញ (Zoom) ស្ដីពី "**ការតម្រង់ទិសឯកសារកម្មវិធីបំណិនជីវិតសម្រាប់បឋមសិក្សា និងមធ្យមសិក្សា**" ដល់សាលារៀនគោលដៅនៅក្នុងខេត្តទាំងបួនជាប់មាត់សមុទ្រ ដូចជា ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ និងខេត្តកោះកុង ដែលមានអ្នកចូលរួមសរុបចំនួន១៦៩នាក់ ដែលជាប្រធានមន្ទីរ-ការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ស្រុក នាយក និងនាយិកា។

វគ្គបណ្ដុះបណ្ដាលនេះមានគោលបំណងតម្រង់ទិសអំពីការប្រតិបត្តិសៀវភៅបំណិនជីវិតទាំង៣៨ក្បាលរបស់ក្រសួង អប់រំ យុវជន និងកីឡាដល់នាយក នាយិកាទាំងពីរកម្រិត។

លោក **នូ វណ្ណសឿន** អនុប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នៃក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា "*បំណិនជីវិតជាកម្មវិធីមួយជួយលើកកម្ពស់គុណភាពរៀនរបស់សិស្សទៅរកជំនាញ និងភាពឯករាជ្យក្នុងសម័យឌីជីថល។ ម្យ៉ាងវិញទៀត ដើម្បីឱ្យមានឧត្តមភាពនៃជីវិត មនុស្សម្នាក់ៗត្រូវមានចិត្តសុខភាពបញ្ញា និងទង្វើឬសកម្មភាព ទើបខ្លួនដឹកនាំនាវាជីវិតកាន់តែល្អប្រសើរ*"។

សាលារៀនគោលដៅនីមួយៗរបស់គម្រោងនឹងរៀបចំផែនការជ្រើសរើសសៀវភៅបំណិនជីវិតមួយចំនួនក្នុងចំណោមបំណិនជីវិតទាំង៣៨ក្បាលយកទៅបង្រៀនសិស្ស ដើម្បីឱ្យពួកគេទទួលបានបំណិនជីវិតពេញបរិបូរណ៍ទៅថ្ងៃអនាគត។ គម្រោង CO-SAVED ប្រឹងប្រែងគាំទ្រប្រព័ន្ធអប់រំមូលដ្ឋាននៅកម្ពុជាពីថ្នាក់ដំបូងនៅកម្រិតបឋមសិក្សាដល់អនុវិទ្យាល័យ។



សាលារៀនគោលដៅខេត្តទាំងបួនជាប់មាត់ចូលរួមវគ្គបណ្ដុះបណ្ដាលតាមប្រព័ន្ធអនឡាញ។

# បំណិនជីវិតទាក់ទងនឹងទឹកស្អាត និងអនាម័យផ្ទាល់ខ្លួន



*សកម្មភាពលោកគ្រូៗពិភាក្សាគ្នាលើរបៀបបង្រៀនពីការប្រើប្រាស់ទឹក និងអនាម័យផ្ទាល់ខ្លួន។*

នៅថ្ងៃទី១០ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០២២ គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា( ស៊ីក/SEEK ) ក្រោមជំនួយហិរញ្ញប្បទានពីសហភាពអឺរ៉ុប បានរៀបចំវគ្គសិក្ខាសាលាស្តីពី **កម្មវិធីបំណិនជីវិត** នៅពីរទីតាំងផ្សេងគ្នាក្នុងខេត្តកំពង់ចាម។ អ្នកចូលរួមសរុបចំនួន៦២នាក់ រួមមាន៖ តំណាងមកពីការិយាល័យអប់រំ យុវជន និងកីឡាស្រុក នាយក នាយិកា និងលោកគ្រូអ្នកគ្រូ។

សិក្ខាសាលានេះធ្វើឡើងដើម្បីឱ្យសិក្ខាកាម៖ **១**-បានស្វែងយល់ពីសាវតា ឧបសម្ព័ន្ធ និងការប្រើប្រាស់សៀវភៅបំណិនជីវិតរបស់ក្រសួងអប់រំយុវជននិងកីឡា។ **២**-អនុវត្តការបង្រៀនសាកល្បងមេរៀនបំណិនជីវិត។ **៣**-ធ្វើផែនការ និងជ្រើសរើសសៀវភៅបំណិនជីវិតសម្រាប់ឆ្នាំថ្មី។

សិក្ខាកាមបានយល់ដឹងពីការប្រើប្រាស់សៀវភៅបំណិនជីវិតស្តីពី ទឹកស្អាត និងអនាម័យផ្ទាល់ខ្លួន។ ទន្ទឹមនឹងនោះ សិក្ខាកាមក៏បានពិភាក្សាគ្នា និងធ្វើការជាដៃគូដើម្បីរៀបចំមេរៀនបង្រៀនសាកល្បងទាក់ទងទៅនឹងប្រធានបទនីមួយៗ ដូចជា ប្រភពទឹក ទឹក វដ្តទឹក បញ្ហាទឹក ការគំរាមកំហែងប្រភពទឹក ជំងឺទាក់ទងនឹងទឹក ការសម្អាតទឹក និងអនាម័យគ្រួសារផ្ទាល់។

តាមសាលារៀនគោលដៅនីមួយៗរបស់គម្រោងនឹងរៀបចំផែនការជ្រើសរើសសៀវភៅបំណិនជីវិតតាមប្រធានបទត្រូវនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋានសម្រាប់បង្រៀនសិស្សនៅក្នុងឆ្នាំសិក្សាថ្មី២០២១-២០២២។ សិក្ខាសាលានេះបានបង្កើតឱកាសច្រើនដល់សិក្ខាកាមដើម្បីលើកយកបញ្ហាប្រឈមនានាមកពិភាក្សាគ្នា និងលើកជាដំណោះស្រាយសម្រាប់អនុវត្តផ្ទាល់៕



*សកម្មភាពលោកគ្រូអ្នកគ្រូពិភាក្សាគ្នាលើប្រភេទជំងឺដែលកើតមានក្នុងប្រភពទឹក។*

អនុវិស័យទី ១០

# កម្មវិធីឆ្លើយតបនឹងវិស័យអប់រំ ក្នុងបរិបទជំងឺកូវីដ-១៩

## Covid19 Response & Recovery Programming



# លើកកម្ពស់ការសិក្សាជាមួយកញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែម

កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំនៅកម្ពុជាក្នុងបរិបទជំងឺកូវីដ-១៩ ដែលគាំទ្រដោយភាពជាដៃគូសកលដើម្បីការអប់រំ ត្រូវបានបិទបញ្ចប់គម្រោងក្នុងឆ្នាំ២០២១ ប៉ុន្តែសមិទ្ធផលសំខាន់ៗ របស់គម្រោង ដូចជា ការអភិវឌ្ឍកញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមភាសាខ្មែរ និងគណិតវិទ្យាចាប់ពីថ្នាក់ទី២ ដល់ទី៦ ត្រូវបាននាយកដ្ឋានអប់រំបឋមសិក្សាបានតាមដាន និងអនុម័តក៏ដូចជាទទួលកញ្ចប់ឯកសារទាំងនោះ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់នៅទូទាំងប្រទេសនៅពេលដែលសាលារៀនបើកដំណើរឡើងវិញក្នុងខែមករា ឆ្នាំ២០២២។

កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមទាំងនោះបានជួយកំណត់ និងវាយតម្លៃសមត្ថភាពសិស្សលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ព្រមទាំងជួយគ្រូបង្រៀនឱ្យវាយតម្លៃឱ្យបានត្រឹមត្រូវ និងកំណត់បាននូវខ្លឹមសារមេរៀនដែលសិស្សរៀនយឺត ដើម្បីធានាបានថាសិស្សរៀនយឺតមានមូលដ្ឋានគ្រឹះសមស្របសម្រាប់បន្តការសិក្សានៅថ្នាក់បន្ទាប់តទៀត។

ក្នុងឆ្នាំ២០២២ អង្គការ ខេប មានគម្រោងមានគម្រោងចំនួន១៨ ដែលក្នុងនោះមានគម្រោងចំនួន៧ ដូចជា គម្រោងសម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌ (CO-SAVED) គម្រោងងាយស្រួលរៀន (E2L) គម្រោងកុមារកម្ពុជារីករាយ (HCC) កម្មវិធីសាលារៀនជំនាន់ថ្មីកម្រិតបឋមសិក្សា (NGSs) គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRACIII) គម្រោងបង្កើនភាពងាយស្រួលដល់ការអប់រំ និងលទ្ធភាពទទួលបានការងារតាមរយៈការចូលរួមពីសហគមន៍ (BMZ) និងគម្រោងពង្រឹងគុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា(EQUAL)ដែលបានយកកញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមទៅធ្វើការផ្សព្វផ្សាយ ដើម្បីឱ្យលោកគ្រូអ្នកគ្រូនៅតាមសាលារៀនគោលដៅយល់ច្បាស់ពីការប្រើប្រាស់ក្នុងគោលបំណងជួយអន្តរាគមន៍បន្ថែមទៅលើសិស្សរៀនយឺត។ ម្យ៉ាងវិញទៀត ឯកសារសិក្សាបំប៉នបន្ថែមក៏ត្រូវបានគម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (SEEK) ប្រើប្រាស់នៅក្នុងកម្មវិធីសិស្សរៀនយឺតនៅសាលាគោលដៅក្នុងខេត្តកំពង់ចាម ត្បូងឃ្មុំ និងកំពង់ឆ្នាំងផងដែរ។ ក្រោយបានបង្រៀនសិស្សតាមឯកសារនេះ សិស្សរៀនយឺតជាច្រើននាក់មានការប្រែប្រួលច្រើន។ លោកស្រី ....ជានាយិកាសាលាបឋមសិក្សាតាមៀង បានមានប្រសាសន៍ថា *"សិស្សរបស់ខ្ញុំបានផ្លាស់ប្តូរវិជ្ជមាន ចំណេះដឹងកើនជាងមុន ជាពិសេសការគិតលេខ ការអាន និងការសរសេរហ៊ានហួន"*។



កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមសម្រាប់ជួយអន្តរាគមន៍សិស្សរៀនយឺត។

កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមទាំងអស់នេះអាចរកបានលើគេហទំព័រមជ្ឈមណ្ឌលសិក្សាតាម រយៈអេឡិចត្រូនិករបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានអាសយដ្ឋានដូចខាងក្រោមនេះ https://elearning.moeys.gov.kh/។ ដូច្នេះ លោកគ្រូអ្នកគ្រូ និងអាណាព្យាបាលសិស្ស អាចទាញយកឯកសារទាំងអស់នេះសម្រាប់ជួយបង្រៀនកុមារនៅផ្ទះ និងបង្កលក្ខណៈងាយស្រួលដល់ពួកគាត់បានរៀន និងបំប៉នបន្ថែមបានគ្រប់ទីកន្លែង៕

# ព្រឹត្តិការណ៍ ចំណេះដឹង កំណាព្យ និងការសិក្សាស្រាវជ្រាវផ្សេងៗ

"ការអភិវឌ្ឍតាមរយៈបណ្ដាញ និងនៅថ្នាក់មូលដ្ឋាន"។

# Events, Knowledge, Poems, and Other Researches

*Development through Networking and Outreach.*













# សិក្ខាសាលាផ្សព្វផ្សាយគម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី

កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG) បានរៀបចំសិក្ខាសាលាស្តីពីការផ្សព្វផ្សាយគម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី តាមរយៈប្រព័ន្ធអនឡាញ (Zoom) ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៧៨នាក់ ដែលជាតំណាងមកពីនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបឋម នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងតំណាងមន្ទីរអប់រំ យុវជន និងកីឡា-ខេត្ត និងលោកគ្រូអ្នកគ្រូ ដែលមកពីរាជធានី/ខេត្តចំនួន២៥ នៅទូទាំងប្រទេស។

គោលបំណងសំខាន់ក្នុងសិក្ខាសាលានេះត្រូវបានរៀបចំឡើងធ្វើការផ្សព្វផ្សាយអំពីសកម្មភាពគម្រោងទៅដល់អ្នកពាក់ព័ន្ធ និងធ្វើការជ្រើសរើសសាលារៀនថ្មីចូលរួមអនុវត្តសាកល្បងកម្មវិធីនៅក្នុងក្របខណ្ឌទូទាំងប្រទេសនៅកម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សា។

លោក **អ៊ុល រុន** ទីប្រឹក្សាជាតិជាន់ខ្ពស់របស់អង្គការ ខេប បានមានប្រសាសន៍ថា "*កម្មវិធី Gap Inc. P.A.C.E ដែលមាន៨ម៉ូឌុល គឺផ្តោតសំខាន់លើការលើកកម្ពស់សមភាពយេនឌ័រ និងមានជំនាញទន់ផ្សេងៗទៀតដែលអាចយកមកប្រើប្រាស់ក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់កុមារ និងយុវជនជំនាន់ក្រោយ បានយល់ដឹងពីបម្រែបម្រួលរាងកាយរបស់ពួកគេតាំងពីកម្រិតបឋមសិក្សា*"។

លោក **រ័ត្ន សារ៉ា** ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈនៃក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា "*បំណិនជីវិត គឺជាបំណិនបញ្ញា បំណិនអន្តរបុគ្គលដែលជួយអភិវឌ្ឍផ្នែកវិជ្ជាជីវៈ អាចធ្វើឱ្យយុវជនចេះដោះស្រាយបញ្ហាដោយខ្លួនឯងបាន យល់ដឹងពីគុណតម្លៃនៃបំណិនជីវិតនឹងរស់នៅប្រកបដោយផលិតភាព ជាពិសេសជួយឱ្យមានសុខមាលភាពសង្គម*"។

លោក **ទុំ ទីតូណា** ប្រធានគម្រោងអប់រំបំណិនជីវិតសម្រាប់កុមារីបានមានប្រសាសន៍ថា "*កត្តាមួយចំនួនដែលជួយឱ្យដំណើរការកម្មវិធីបំណិនជីវិត Gap Inc. P.A.C.E. ទទួលបានជោគជ័យ គឺមានការគាំទ្រពីនាយក នាយិកា សាលាមានបន្ទប់រៀនគ្រប់គ្រាន់ មានគ្រូទទួលបន្ទុកផ្នែកបំណិនជីវិត ក្រុមសិស្ស និងមានម៉ោងបំណិនជីវិតសម្រាប់បង្រៀន ឬប្រើប្រាស់ម៉ោងដែលសិស្សទំនេរក្នុងការបង្រៀន*"។

គម្រោងនឹងជ្រើសរើសសាលារៀនគោលដៅថ្មីចំនួន៥០នៅទូទាំងប្រទេស និងបានស្នើសុំកិច្ចសហការពីមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ស្រុក ក៏ដូចជាអ្នកពាក់ព័ន្ធក្នុងដំណើរការជ្រើសរើសសាលារៀនក្នុងតំបន់របស់ខ្លួន និងផ្ញើឈ្មោះសាលារៀនទាំងអស់នោះមកកាន់នាយកដ្ឋាន ឬមន្ត្រីគម្រោងផ្ទាល់ ដើម្បីធ្វើការបូកសរុបចំនួនសាលារៀនដែលគម្រោងមានលទ្ធភាពជួយគាំទ្របានក្នុងការអនុវត្តកម្មវិធីបំណិនជីវិតសម្រាប់កុមារី។ កម្មវិធីនេះមានសៀវភៅចំនួន៨ម៉ូឌុលបែងចែកជាពីរផ្នែកគឺសម្រាប់សិស្សវ័យជំទង់ អាយុ១១ដល់១៣ឆ្នាំ និងសិស្សពេញវ័យ អាយុ១៤ដល់១៧ឆ្នាំដែលផ្តោតទៅលើអារម្មណ៍ និងមិត្ត ភាព អំពីហិង្សា និងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាដើម។ល។



*សកម្មភាពសិក្ខាកាមចូលរួមទាំងនៅក្នុងប្រព័ន្ធអនឡាញ និងនៅការិយាល័យកណ្តាលរបស់អង្គការ ខេប។*

# កិច្ចប្រជុំស្តីពីការពិនិត្យសកម្មភាពក្នុងការគាំទ្រវិទ្យាជាតិអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកិច្ចប្រជុំស្តីពីការពិនិត្យសកម្មភាពក្នុងការគាំទ្រវិទ្យាស្ថានជាតិអប់រំ និងសាលាមធ្យមសិក្សាធនធាននៃគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP-II) កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ ដោយមានសមាសភាពចូលរួមសរុបចំនួន៣៧នាក់ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងវត្តមានចូលរួមពីថ្នាក់ដឹកនាំគ្រប់គ្រងគម្រោង មន្ត្រីសម្របសម្រួល និងអនុវត្តគម្រោង។

កិច្ចប្រជុំនេះផ្តោតសំខាន់ទៅលើការពិនិត្យលើសកម្មភាពគាំទ្រវិទ្យាស្ថានជាតិអប់រំ ផ្តោតលើការជួសជុល និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការសាងសង់បណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត និងនីតិវិធីមួយចំនួនដើម្បីលើកកម្ពស់គុណភាពគ្រូបង្រៀននៅកម្រិតមធ្យមប្រកបដោយប្រសិទ្ធភាព។

នៅចុងឆ្នាំ២០២០ អង្គការ ខេប បានចុះកិច្ចសន្យាជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់ការគាំទ្របច្ចេកទេសដល់កម្មវិធីថ្នាក់ជាតិដ៏ធំមួយមានឈ្មោះថា កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ២ ដែលជាគម្រោងដ៏ធំមួយធ្វើការងារលើការធ្វើទំនើបកម្មមធ្យមសិក្សា ជាពិសេសទាក់ទងនឹងសាលាធនធាននៅមធ្យមសិក្សាចំនួន៥០ ដែលត្រូវបានអភិវឌ្ឍឡើងក្រោមគម្រោង ផ្សេងៗពីមុន។ គម្រោងនេះក៏គាំទ្រសាលារៀនបណ្តាញចំនួន៨៧ផងដែរដោយផ្អែកលើជំនួយបច្ចេកទេសដល់សាលាធនធានមធ្យមសិក្សា។ គម្រោង USE-SDP2 បានទទួលជំនួយហិរញ្ញប្បទានក្រោមកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ីចំនួន៥៣,៥លានដុល្លារអាមេរិក។ ការងាររបស់អង្គការ ខេប គឺកំណត់បាននូវវិសាលភាពយ៉ាងទូលំទូលាយចំពោះការអភិវឌ្ឍ និងការផ្តល់ឯកសារបណ្តុះបណ្តាលដែលខ្លឹមសារបណ្តុះបណ្តាលត្រូវបានតាមដានពិនិត្យដោយទីប្រឹក្សាប្រចាំតំបន់។

កិច្ចសន្យារបស់អង្គការ ខេប នៅពេលបច្ចុប្បន្នមានសុពលភាពរយៈពេល៣ឆ្នាំ និងហេតុផលសំខាន់មួយសម្រាប់ការសម្រេចចិត្តរបស់ក្រសួងអប់រំ យុវជន និងកីឡាឱ្យអង្គការ ខេប ចូលរួមអនុវត្តគម្រោង USE-SDP2 ដើម្បីប្រើប្រាស់ការច្នៃប្រឌិតជាច្រើនក្រោមកម្មវិធីសាលារៀនជំនាន់ថ្មី។ ដូច្នេះ សាលាមធ្យមសិក្សាជាច្រើនទៀតអាចចម្លង និងយកទៅអនុវត្តបាន។

គម្រោង USESDP2 ជួយដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តកម្មវិធីសាលារៀននៅទូទាំងប្រទេសឱ្យកាន់តែប្រសើរឡើង ជាពិសេសបានផ្តួចផ្តើមកំណែទម្រង់គោលនយោបាយក្នុងវិស័យអប់រំ ដោយផ្តោតសំខាន់លើការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ និងដើម្បីសម្រេចបាននូវលទ្ធផលកម្មវិធីចំនួន៣ ដូចខាងក្រោម៖ **១**-គុណភាពគ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិកាន់តែល្អឡើង។ **២**-គុណភាព និងបំណិនពាក់ព័ន្ធទីផ្សារការងារនៅមធ្យមសិក្សាទុតិយភូមិ មានការកែលម្អ និង **៣**-ការពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ធ្វើផែនការគ្រប់គ្រង និងការផ្តល់សេវាកម្មអប់រំឱ្យកាន់តែមានភាពរឹងមាំទ្វេឡើង និងមានប្រសិទ្ធផលខ្លាំង៕



*កិច្ចប្រជុំនេះត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។*

# ពិធីបើកសម្ពោធគម្រោងលើកកម្ពស់គុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា

គម្រោងលើកកម្ពស់គុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា (EQUAL) គឺជាគម្រោងថ្មីមួយរបស់អង្គការ ខេប ដែលបានបើកសម្ពោធដំណើរគម្រោងជាផ្លូវការនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ នៅមន្ទីរអប់រំ យុវជន និងកីឡា ខេត្តរតនគិរី ក្រោមអធិបតីភាពលោក ហ៊ិន ស៊ីមហួន នាយករងប្រតិបត្តិ និងប្រធានបច្ចេកទេសរបស់អង្គការខេប។ ពិធីនេះមានអ្នកចូលរួមសរុបចំនួន៥២នាក់ ដែលជាប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ប្រធានការិយាល័យបឋមសិក្សា នាយក នាយិកា លោកគ្រូ អ្នកគ្រូ គណៈកម្មាការគ្រប់គ្រងសាលារៀន ក្រុមប្រឹក្សាឃុំ និងប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកបរកែវ និងអណ្តូងមាស។



លោក ហ៊ិន ស៊ីមហួន នាយករងប្រតិបត្តិ អង្គការ ខេប ក្នុងអំឡុងពេលថ្លែងសុន្ទរកថាបើកសម្ពោធគម្រោង EQUAL ក្នុងខេត្ត រតនគិរី។

គោលបំណងរបស់គម្រោង ដើម្បី៖ ១-ពង្រឹងគុណភាអប់រំ និងការចូលរួមនៅកម្រិតអប់រំជាមូលដ្ឋានកើនឡើងក្នុងចំណោមក្រុមងាយរងគ្រោះ ដូចជា កុមារីក្រុមជនជាតិភាគតិច ជនពិការ និងជនក្រីក្រ។ ២-ធ្វើឱ្យកុមារនៅក្រៅសាលារៀន និងកុមារជនជាតិភាគតិចក្នុងខេត្តរតនគិរីមានឱកាសបំពេញសិទ្ធិក្នុងការអប់រំនៅបឋមសិក្សា និងបន្តទៅអនុវិទ្យាល័យដោយរលូនតាមរយៈការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងផ្លាស់ប្តូរបែបយេនឌ័រ។

គម្រោង EQUAL នឹងអនុវត្តនៅសាលារៀនគោលដៅចំនួន១៥ស្ថិតក្នុងស្រុកចំនួនពីរនៅជាប់ព្រំដែនវៀតណាមក្នុងខេត្តរតនគិរី ហើយការប្រតិបត្តិរបស់គម្រោងនឹងចូលរួមដោះស្រាយបញ្ហាប្រឈមដែលទាក់ទងទៅនឹងគុណភាពអប់រំ បរិយាបន្ន ជាពិសេសកុមារីក្រុមងាយរងគ្រោះ កុមារីជនជាតិដើមភាគតិច និងកុមារក្នុងគ្រួសារក្រីក្រ។

ពិធីបើកសម្ពោធគម្រោង EQUAL បានប្រព្រឹត្តទៅដោយជោគជ័យ និងទទួលបានការគាំទ្រការចូលរួមការសហការយ៉ាងល្អពីអាជ្ញាធរមូលដ្ឋាន នាយក នាយិកា លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធរបស់គម្រោងក្នុងការអនុវត្តផែនការសកម្មភាពឱ្យសម្រេចបានតាមគោលដៅ។ គម្រោង EQUAL នឹងពង្រឹងទីភ្នាក់ងាររបស់ក្មេងស្រី និងស្ត្រីវ័យក្មេង ដោយធ្វើការដើម្បីផ្តល់សិទ្ធិអំណាចដល់ក្មេងស្រី និងក្មេងប្រុសតាមរយៈការផ្តល់នូវឧបករណ៍អនុវត្តជាក់ស្តែង ដើម្បីធ្វើការសំរេចចិត្តប្រកបដោយការយល់ដឹងច្រើននាពេលអនាគតរបស់ពួកគេ៕



កម្រងរូបភាពថតជុំគ្នាបន្ទាប់ពីកម្មវិធីសម្ពោធគម្រោងត្រូវបានបញ្ចប់ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ខេត្តរតនគិរី ។

# កម្មវិធីបើកសម្ពោធគម្រោងបង្កើនភាពងាយស្រួលដល់ការអប់រំ និងលទ្ធភាពទទួលបានការងារតាមរយៈការចូលរួមពីសហគមន៍( BMZ )

នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ អង្គការ ខេប បានសហការជាមួយអង្គការដៃគូ រួមមាន៖ អង្គការគាំទ្រផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW) និងអង្គការវីវើល-ជីវីស៊ី (WeWorld-GVC) រៀបចំកម្មវិធីសម្ពោធគម្រោងបង្កើនភាពងាយស្រួលដល់ការអប់រំ និងលទ្ធភាពទទួលបានការងារតាមរយៈការចូលរួមពីសហគមន៍ (BMZ) នៅក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាពលោកស្រី គង់ សុភាវត្តី អនុប្រធាននាយកដ្ឋានបឋមសិក្សានៃក្រសួងអប់រំយុវជននិងកីឡា។

កម្មវិធីនេះមានបំណងផ្សព្វផ្សាយអំពីគម្រោង BMZ ដល់ប្រធាន/អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ក្រុមគោលដៅ និងអ្នកពាក់ព័ន្ធមកពីខេត្តស្វាយរៀង ព្រៃវែង កំពង់ឆ្នាំង និងពោធិ៍សាត់។




*លោក ហ៊ិន ស៊ីមហួន នាយករងប្រតិបត្តិ និងប្រធានបច្ចេកទេសនៃអង្គការ ខេប បានថ្លែងសុន្ទរកថាបើកសម្ពោធគម្រោង BMZ នៅរាជធានីភ្នំពេញ។*

គម្រោង BMZ មានគោលបំណងរួមចំណែកដល់ការបំពេញសិទ្ធិសង្គម និងសេដ្ឋកិច្ចដល់កុមារ និងយុវជនដែលងាយរងគ្រោះនៅកម្ពុជា ដែលប្រឈមនឹងហានិភ័យនៃការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព។

គម្រោង BMZ ទទួលបានជំនួយហិរញ្ញប្បទានពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍរបស់ប្រទេសអាឡឺម៉ង់តាមរយៈអង្គការឆាលហ្វាន Deutschland (ឆាលហ្វានអាឡឺម៉ង់) និងប្រតិបត្តិការដោយអង្គការ ខេប អង្គការ LSCW និងអង្គការវីវើលនៅក្នុងខេត្តគោលដៅចំនួន៤ រួមមាន៖ ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់៕

---

# ខេបបានចូលរួមទទួលពានរង្វាន់ Lotus Leadership នៅក្នុងទីក្រុងញូវយ៉ក




*លោក សៅ វណ្ណា នាយកប្រតិបត្តិអង្គការខេប បានថ្លែងសុន្ទរកថាស្តីពីសកម្មភាពគម្រោងកំពុងប្រតិបត្តិ ជាពិសេសលើការជួយគាំទ្រកុមារី និងស្ត្រីងាយរងគ្រោះឱ្យទទួលបានការអប់រំ។*

នៅថ្ងៃទី០៦ខែមេសា ឆ្នាំ២០២២ នាយកប្រតិបត្តិ ប្រធានសម្របសម្រួលកម្មវិធីអប់រំបរិយាបន្ន និងអតីតនិស្សិតអាហារូបករណ៍របស់អង្គការ ខេប បានចូលរួមកម្មវិធីទទួលពានរង្វាន់ Lotus Leadership Award នៅសណ្ឋាគារ Oriental Mandarin ជាន់ទី៣៤ ស្ថិតក្នុងទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក តាមការអញ្ជើញរបស់អង្គការមូលនិធិអាស៊ី ដើម្បីធ្វើការទទួលស្គាល់ការងារសំខាន់ៗរបស់អង្គការខេបក្នុងការលើកកម្ពស់ការអភិវឌ្ឍ និងភាពជាអ្នកដឹកនាំដល់ស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះ។ ពិធីប្រគល់ពានរង្វាន់នេះបានផ្តល់ឱកាសឱ្យខេបបាននិយាយទៅកាន់ឥស្សរជនក្នុងកម្មវិធីឱ្យបានដឹងអំពីសកម្មភាពរបស់អង្គការក្នុងការជួយអន្តាគមន៍ និងគាំទ្រដល់ក្រុមកុមារី និងយុវនារីដែលងាយរងគ្រោះឱ្យមានឱកាសទទួលបានការអប់រំគ្រប់គ្រាន់តាមរយៈគម្រោងអប់រំកុមារី( GEI )ដែលមានរយៈពេលយូរក្នុងការអនុវត្តសកម្មភាពរបស់ខ្លួន និងកម្មវិធីអាហារូបករណ៍ថ្នាក់ឧត្តមសិក្សា (CTSP) ដែលមានកញ្ញា ស៊ីម ផល្លី ជាអតីតសិស្សអាហារូបករណ៍គម្រោង និងបច្ចុប្បន្ននេះ កញ្ញាកំពុងតែធ្វើការនៅក្នុងអង្គការ ខេប កាន់តួនាទីជាប្រធានក្រុមគម្រោង GEI។ ក្រោយពីបានផ្តល់សុន្ទរកថាបង្ហាញអំពីអ្វីដែលអង្គការ ខេប បានកំពុងប្រតិបត្តិមក មានការសាទរ និងស្វាគមន៍អបអរសាទរយ៉ាងកក់ក្តៅពីទស្សនិកជន ហើយជាសញ្ញាដ៏ល្អមួយសម្រាប់អង្គការក្នុងការស្វែងធនធានដើម្បីគាំទ្រកម្មវិធីរបស់អង្គការ។

អ្វីដែលគួរឱ្យចាប់អារម្មណ៍ អ្នកដែលមានវត្តមាននៅក្នុងពិធីនេះបានបរិច្ចាគជិតថវិកាប្រមាណជា ៧០០ ០០០ដុល្លារអាមេរិកដល់អង្គការមូលនិធិអាស៊ីសម្រាប់កម្មវិធី (រួមទាំងខេប ) ក្នុងរយៈពេលប្រហែលមួយម៉ោង។ នេះជាព្រឹត្តិការណ៍ដ៏អស្ចារ្យ និងមានសារៈសំខាន់សម្រាប់អង្គការ ខេប ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន៕

## នាមសិស្សានុសិស្ស

(បទ ពាក្យប្រាំពីរ)

១. នេះសុំចារចែងតែងកំណាព្យ  វោហាតាមកាព្យជាឃ្លោងឃ្លា
ជូនដល់កុលបុត្រធីតាភ្វា  ទុកជាមាគ៌ាក្រើនរំឭក។
២. អំពើប្រព្រឹត្តត្បិតចិត្តយើង  បើចង់បានថ្កើងគួរកុំភ្លឹក
កុំភ្លាត់ស្មារតីភ្លាត់ការគិត  ហ្វឹកហាត់គំនិតនោះទើបជា។
៣. ដើរតាមអ្នកប្រាជ្ញក្លាយបណ្ឌិត  តាមជនឧក្រិដ្ឋចិត្តពាលា
ប្រព្រឹត្តអំពើទង្វើពាល  សង្គមតិះដៀលគួរបង្ការ។
៤. យកពេលទៅចោលឥតគំនិត  លេងគ្មានការគិតឥតបានការ
ឥតបានប្រយោជន៍ដល់មនុស្សណា នោះហើយបញ្ហាគួរកុំឆ្ងល់។
៥. កិត្តិយសមាសប្រាក់និងកេរ្តិ៍ឈ្មោះ  បុណ្យសក្តិសក្តិយសក៏ពុំដល់
ប្រសិនបើយើងនៅត្រដរ  ចាំវាមកដល់មិនប្រសើរ។
៦. គួរតែសិក្សាយកចំណេះ  ជំនាញឲ្យចេះអាចយកប្រើ
អក្សរសាស្រ្តគាប់ប្រសើរ  វិទ្យាសាស្រ្តអមដើរឆ្ពោះជោគជ័យ។
៧. គំនូរសិល្បៈច្បាស់សំខាន់  បើយើងចាប់កាន់ឲ្យតម្លៃ
របាំរបៀនមានកែច្នៃ  វប្បធម៌ប្រពៃចេះឲ្យជាក់។
៨. បំណិនអំណានប្រានការគិត  ឲ្យមានគំនិតគិតជ្រៅរាក់
ប្រវត្តិភូមិសាស្រ្តត្រូវឲ្យជាក់  ត្រូវចេះវារៈរៀបបែងចែក។
៩. សិក្សាបន្ថែមតាមអនឡាញ  តាមទាន់ឲ្យបាននូវបច្ចេក-
វិទ្យាសិក្សាបានគ្រប់ផ្នែក  គ្រប់មុខតាមបែបតាមវិជ្ជា។
១០. សង្គមដើរលឿនព្រោះអ្នករៀន  គេចែករបៀនមានមុខងារ
យើងគួរចាប់យកគ្រប់វិជ្ជា  ឲ្យចាំចេះជាជាប់គំនិត។
១១. គេមានមេរៀនមានវិញ្ញាសា  ខំបង្កើតណាព្រោះនិស្សិត
គេខំផ្សព្វផ្សាយគ្រប់គំនិត  ទៅតាមកម្រិតចែកទៅសិស្ស។
១២. ក្រសួងអប់រំរួមសហការ  បញ្ចេញវិញ្ញាសាឲ្យនុសិស្ស
ដើម្បីយករៀនមានជម្រើស  ប្រើតាមការជ្រើសតាមត្រូវការ។
១៣. ម្លោះសានុសិស្សគួរខំរៀន  ឲ្យទាន់ជំហានសម័យកាល
ចេះមានជំនាញយកប្រើការ  សង្គមគ្រួសារពឹងលើបាន។
១៤. ចំណេះទាំងអស់អាចបានការ  លុះត្រាចេះច្បាស់ចងចាំបាន
កុលបុត្រធីតាយើងគ្រប់ប្រាណ  គួរតែធ្វើបានតាមការគួរ។

*និពន្ធដោយៈ កុយ កក្កដា*
*សិស្សថ្នាក់ទី១២ សាលារៀនជំនាន់ថ្មី(កំពង់ចាម)*

## កូរ៉ូណាប្រល័យការសិក្សាខ្ញុំ២០២១ !

(បទ កាកគតិ)

ឱកម្ពុជាអើយ  ថ្ងៃណាទៅស្បើយ  មេរោគចង្រៃ
កូរ៉ូណាវីរុស  ឬកូវីដថ្មី  មេរោគប្រល័យ
ការសិក្សាខ្ញុំ។

គ្រប់អ្នកសិក្សា  ស្វះស្វែងកាយា  រាវរកសមរម្យ
សាលាក៏បិត  លែងបានជំនុំ  លែងបានជួបជុំ
ទាំងគ្រូទាំងមិត្ត។

ទោះបីយ៉ាងណា  សិស្សតាំងចិន្តា  ខិតខំតាំងចិត្ត
ខិតខំរៀនសូត្រ  នៅផ្ទះចំណិត  សួរម៉ែពុកពិត
មិនចាញ់គ្រូណា។

រៀននៅឯផ្ទះ  ត្រូវមិនខ្វាយខ្វះ  នៅពេលវេលា
សិក្សាស្វែងយល់  ដោយខ្លួនអាត្មា  ថែមទាំងរក្សា
នូវសុខភាពផង។

រៀនហើយរៀនទៀត  រៀនកុំឱ្យឃ្លាត  រៀនជាចម្បង
រៀនទាំងអក្សរ  រៀនទាំងលេខផ្ទង់  រៀនតាមចំណង់
ដែលយើងត្រូវការ។



*ស្នាដៃនិពន្ធដោយ ថា លីដា សិស្សថ្នាក់ទី១០*
*សាលារៀនជំនាន់ថ្មីវិទ្យាល័យហ៊ុន សែន ពាមជីកង*

*"ការអប់រំ គឺជាអាវុធដ៏សំខាន់បំផុតដែលអាចឱ្យអ្នកប្រើប្រាស់វាដើម្បីផ្លាស់ប្តូរពិភពលោក"។*

**នែលសិន មែនដេឡា** ( Nelson Mandela )

# ទម្រាំតែអាចរស់មកដល់ថ្ងៃនេះ!

ទម្រាំតែរស់បានមកដល់ថ្ងៃនេះ យើងបានរស់ទាំងលំបាកក៏យូរណាស់មកហើយ ប៉ុន្តែវានៅមានពេលវេលាយូរជាងហ្នឹងទៀត ដែលយើងត្រូវជួបនូវរឿងថ្មីៗ ហើយត្រូវដោះស្រាយ។ ឧបសគ្គជីវិតប្រៀបដូចជណ្តើររាប់យកាំ ឬផ្លូវឡើងទៅលើកំពូលភ្នំ ដែលយើងត្រូវដើរកាត់។ ជាន់ឡើងមួយកាំយើងនឹងទៅបានខ្ពស់ជាងមុនបន្តិច ឈានមួយជំហានយើងនឹងទៅបានឆ្ងាយជាមុនបន្តិច។ អាចឈានទៅមុខយឺតៗបន្តិចក៏បាន ប្រសិនបើយើងហត់នឿយ។ អាចបកក្រោយក៏បាន ប្រសិនបើយើងគិតថាមានផ្លូវថ្មីដែលល្អជាងនេះ។ អាចផ្លាស់ប្តូរមធ្យោបាយធ្វើដំណើរក៏បាន ប្រសិនបើវាមានជម្រើស។ ប៉ុន្តែប្រសិនបើយើងមិនអាចជ្រើសរើសបានទេ អ្វីម្យ៉ាងដែលយើងអាចធ្វើបានគឺការអត់ទ្រាំ។ នាវាមួយទម្រាំតែអាចទៅដល់ត្រើយបាន វាក៏ត្រូវឆ្លងកាត់រលកធំៗកណ្តាលមហាសមុទ្រ ឆ្លងកាត់ព្យុះ ភ្លៀង និងភាពភ័យខ្លាចជាច្រើន។ នៅលើវិថីជីវិតឆ្ពោះទៅរកគោលដៅមួយដែលយើងបានកំណត់ វាមិនងាយស្រួលដូចអ្វីដែលយើងគិតទេ។ វាត្រូវតែឆ្លងកាត់ភាពលំបាក និងឧបសគ្គច្រើនលើកច្រើនសារណាស់ ប៉ុន្តែពេលវេលាដែលឆ្លងកាត់មកនេះ វាពិតជាបានបង្រៀនយើងច្រើនមែនទែន។ ប្រឡូកក្នុងសង្គមឲ្យច្រើនទៀត ព្រោះមានមនុស្សក្នុងសង្គមនេះច្រើនណាស់ ដែលយើងមិនទាន់បានស្គាល់គេនៅឡើយ ប៉ុន្តែយើងក៏ត្រូវតែសង្កេត និងកសាងខ្លួនឯងជាមុនសិនដែរ។

រឿងសំខាន់បំផុតក្នុងជីវិត គឺការរៀនគ្រប់គ្រងចិត្តរបស់ខ្លួនឲ្យបាន បើមិនដូច្នេះទេ វានឹងគ្រប់គ្រងយើងវិញមិនខាន។ គ្រប់គ្រងពាក្យសំដីមិនច្រឡោតដើម្បីតែឈ្នះ គ្រប់គ្រងចិត្តមិនសម្រេចភ្លាមៗព្រោះតែកំហឹង គ្រប់គ្រងកាយវិការ មិនប្រងេងប្រងាង ទោះជាកំពុងខឹងក្តី។ កើតជាមនុស្ស នរណាក៏ចេះខឹងដែរ ប៉ុន្តែអ្វីដែលខុសគ្នាគឺការគ្រប់គ្រងកំហឹងក្នុងចិត្ត។ បើគ្រប់គ្រងវាមិនបានទេ ក៏មិនអាចបន្ទោសអ្នកណា ថាគេមកសម្លាប់យើងដែរ ពីព្រោះកំហឹងនៅក្នុងចិត្តយើងនេះ វាសាហាវជាងសត្រូវ១០០នាក់នៅខាងក្រៅខ្លួនទៅទៀត៕

*(ដកស្រង់ចេញពីផេក #កូនចាបមាស)*



រូបភាព #Pinterest

# មតិអ្នកអាន



ខ្ញុំមានអារម្មណ៍សប្បាយរីករាយឥតឧបមាដែលសាលាបានសហការជាមួយអង្គការខេប ក្នុងការជួយអភិវឌ្ឍន៍សាលា ធ្វើឱ្យថ្នាក់រៀនស្អាតមានរបៀបហើយមានលក្ខណៈគរុកោសល្យ។ តាមការសង្កេតរបស់ខ្ញុំ សិស្សចូលចិត្តមករៀនពេលដែលមានបរិស្ថានស្អាតជុំវិញដែលឈានទៅរកសាលាបែបកុមារមេត្រីរួមផ្សំជាមួយលោកគ្រូអ្នកគ្រូកាន់តែយកចិត្តទុកដាក់ក្នុងការបង្រៀន។ អង្គការ ខេប គឺជាអង្គការដៃគូដ៏ល្អបំផុតដែលជួយសាលាចំគោលដៅឱ្យឆ្ពោះទៅកាន់សាលាមេត្រីនៅថ្ងៃមុខៗ។

ជាចុងក្រោយសូមអរគុណអង្គការ ខេប ដែលបានជួយគាំទ្រសាលាឱ្យមានការរីកចម្រើនទាំងក្នុងថ្នាក់និងក្រៅថ្នាក់ ដើម្បីជំរុញឱ្យកុមារមករៀនកាន់តែច្រើន៕

*អ្នកគ្រូ កែវ សេដ្ឋា*
*នាយិកាសាលាបឋមសិក្សា ទូយ ខេត្តរតនៈគិរី*